BMI0029

# សម្ភាសន៍ជាមួយឈ្មោះ ដួន ម៉ុន ភេទស្រី អាយុ៥៦ឆ្នាំ

មុខងាររសម័យខ្មែរក្រហមៈ ប្រធានផ្នែកអន្ទងនិងល្ងឹងអំបោះនៅរោងចក្រតម្បាញត-១

មុខងាររបច្ចុប្បន្នៈ មេភូមិដូង

ស្រុកកំណើតនៅភូមិត្រពាំងស្វាយ ឃុំក្រាំងម្កាក់ ស្រុកអន្លង់ស្នួល ខេត្តកណ្តាល

សព្វថ្ងៃរស់នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឆាយ ឃុនលី

០១:២៥:១១

៣៥ទំព័រ

ឃុនលី ៈ មីងឈ្មោះ អីគេ?

ម៉ុន ៈ ដួន ម៉ុន ។

ឃុនលី ៈ អាយុប៉ុន្មាន?

ម៉ុន ៈ អាយុ៥៦ ។

ឃុនលី ៈ មីងនៅភូមិ?

ម៉ុន ៈ ដូង ។

ឃុនលី ៈ មីងមេភូមិ?

ម៉ុន ៈ ចា៎!

ឃុនលី ៈ មីងមានស្រុកកំណើតនៅណា?

ម៉ុន ៈ ស្រុកកំណើតនៅស្រុកអន្លង់ស្នួល ខេត្តកណ្តាល ។

ឃុនលី ៈ ឃុំអីគេ?

ម៉ុន ៈ ឃុំក្រាំងម្កាក់ ។

ឃុនលី ៈ ភូមិអីគេ?

ម៉ុន ៈ ភូមិត្រពាំងស្វាយ ។

ឃុនលី ៈ មីងមានបងប្អូនប៉ុន្មាននាក់?

ម៉ុន ៈ បងប្អូន៣នាក់ ។

ឃុនលី ៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

មុំន ៖ ស្រីតែម្នាក់ ។

ឈុនលី ៖ ឪពុកម្ដាយមីងធ្វើអីទៅ?

មុំន ៖ ឪពុកម្ដាយធ្វើស្រែ តែគាត់ស្លាប់តាំងពីអាយុ៧-៨ឆ្នាំដឹង នឹងឪពុកនៅម្ដាយ ។

ឈុនលី ៖ គាត់ស្លាប់ដោយសារអីគេ?

មុំន ៖ ស្លាប់កាលជំនាន់យើងក្មេងយើងមិនសូវដឹងដែរ ។

ឈុនលី ៖ តែកាលនឹងមានដល់ជំនាន់ពតឆ្នាំ?

មុំន ៖ អត់ទេ ព្រោះយើងនៅតូច ខ្ញុំចេញមកអាយុ នៅឆ្នាំ៧០គត់នឹងអាយុ១៥-១៦ ។

ឈុនលី ៖ ៧០គត់នឹង មីងចេញទៅណា?

មុំន ៖ ចេញមក ថាតស៊ូចុះជំនាន់នឹង ។

ឈុនលី ៖ ឆ្នាំ៧០គត់មីងចូលតស៊ូ?

មុំន ៖ ចាំ!

ឈុនលី ៖ ម៉េចក៏ចូលតាំងពី៧០គត់នឹង ៧០ដល់៧៥គត់ជំនាន់លន់ នល់ ៧៥ដល់៧៩បានជំនាន់ខ្មែរក្រហម ហើយបានបន្ត?

មុំន ៖ ហ្នឹងហើយ ជំនាន់លន់ នល់ ជំនាន់យើងទម្លាក់គ្រាប់បែក ។

ឈុនលី ៖ ពេលមីងចូលនឹងដោយការជំរុញពីណាគេ?

មុំន ៖ អត់ៗមានជំរុញទេ មានបងមួយ ។

ឈុនលី ៖ គេប្រកាស?

មុំន ៖ អត់ប្រកាសទេ ព្រោះយើងនៅផ្ទះយើងមិនមែនផ្ទះនៅព្រៃណា ផ្ទះនៅជិតថ្នល់ជាតិ បើនិយាយថាជាយក្រុងភ្នំពេញដែរ ។ ដល់ពេលមានបងប្រុសនឹង គាត់ទៅតស៊ូនៅយើង គាត់ទៅ៧០គត់ដែរនឹង តែខ្ញុំទៅក្រោយ ។

ឈុនលី ៖ គេហៅចូលធ្វើទាហានខាងខ្មែរក្រហមម៉ង?

មុំន ៖ ខាងខ្មែរក្រហម ។

ឈុនលី ៖ គេចូលព្រៃចូលអី?

មុំន ៖ ចូលដែលទៅចូលព្រៃ ។

ឈុនលី ៖ ព្រៃអីគេ?

មុំន ៖ ព្រៃនៅខាងកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

ឈុនលី ៖ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល?

មុំន ៖ ចាំ!

ឈុនលី ៖ ចូលទៅហូបចុកអីម៉េចទៅ?

ម៉ុន ៖ ចូលទៅជំនាន់នឹងហូបចុកអីធម្មតា អត់មានអីទេ គ្រាន់យើងនៅមន្ទីរមានមេមានអី ខ្ញុំនៅហូបធម្មតាទៅ តែយើងមានទៅណា យើងស្រី នៅតែជាមួយគេទៅ ស្ពាយគ្រាប់ប្លោងអីមក យើងចូកត្រង់សេរ ។ ទាល់បានរវាង២-៣ខែ យើងចាប់ផ្ដើមរៀនពេទ្យ តែរៀនពេទ្យនឹងអត់មានបច្ចេកទេសអីដូចគេបើកសាលាបង្ហាត់រៀនពេទ្យទេ គំនិតដូចខ្ញុំនិយាយថាដុះខ្លួនឯង ឃើញគេនៅនឹងទៅចេះមើលគេមើលឯងចេះទៅ ។ ដល់ពេលព្យាបាល កាលនោះគេហៅមិត្តៗ ពេលមិត្តយើងគ្រុនរងា ឬត្រូវរបួស យើងចាក់ថ្នាំថាអត់ចេះអក្សរអង់គ្លេស បារាំងអីទេ តែចាក់ថ្នាំតាមយើងចំណាំដូចថា វីតាមីសេនមានអក្សរសេខាងមុខកានីន ចំណាំអក្សរអោអ៊ិន យើងចាំណាំអីចឹង ។

ឈុនលី ៖ កាលមីងចូលមកតស៊ូនឹង ធ្វើពេទ្យបណ្ដោយ?

ម៉ុន ៖ ហ្នឹងហើយ អត់មានទៅបានធ្វើអីទេ ។

ឈុនលី ៖ អត់អ្នកដញ្ជូនសម្ភារៈដូចគេ?

ម៉ុន ៖ អត់ ។

ឈុនលី ៖ អាយុប៉ុន្មានហើយ កាល?

ម៉ុន ៖ ជំនាន់ខ្ញុំអាច១៤-១៥ តាំងពីនឹងមក មីងអាយុ៥៦ហើយ ។

ឈុនលី ៖ ដល់ពេលនៅនឹងមានបងប្រុស?

ម៉ុន ៖ បងប្រុសគាត់ធ្វើទាហានដែលគំនិតបានមកនឹង គាត់អត់មានចលនាថាប្អូនអើយ!ត្រូវមកតស៊ូជាមួយបងជាមួយអីអត់ទេ ព្រោះគាត់ចេញទៅក៏ខ្ញុំអត់ដឹងដែរ តែចេះបាត់យូរៗទៅក៏គេចេះថាបងឯងទៅនៅខាងកណ្ដាលស៊ីងហើយ ឥឡូវចង់ទៅលេងអត់ បើចង់ទៅលេងពូមីងនាំទៅខ្ញុំទៅៗ ។ ដល់ទៅក្រាបគ្រាប់ប្លោងផងអីផង ដល់គាត់ក៏ចំលងឲ្យទៅនៅមន្ទីរទៅ ស្រុក ។

ឈុនលី ៖ មីងរៀនប៉ុន្មានខែចេះចាក់ថ្នាំ គេឲ្យចាក់?

ម៉ុន ៖ បើនិយាយទៅរៀនបណ្ដើរចាក់បណ្ដើរគំនិតដូចខ្ញុំថាអីចឹងឯង អត់មានបានបច្ចេកទេសរៀនសូត្រអី ជម្ងឺគ្រុនចាញ់គេមើលរបៀបម៉េចអីអត់ជំនាន់យើងនឹង ។

ឈុនលី ៖ ចុះកាលនឹងនៅប្រើថ្នាំពេទ្យ អត់ទាន់នៅប្រើថ្នាំអាចម៍ទន្សាយ?

ម៉ុន ៖ អត់ទេ ប្រើថ្នាំពេទ្យយើងធម្មតា ប្រើគីនីន អាថ្នាំគេវ៉ៃមេរោគ អាគេហៅថ្នាំមូស វ៉ៃអានឹង ។

ឈុនលី ៖ ហើយដូចទៅនៅក្នុងព្រៃ គេធ្វើខ្ទមធ្វើអីឲ្យនៅ?

ម៉ុន ៖ ធ្វើផ្ទះ គេហៅមន្ទីរតូចៗផ្ទះតូចៗ មានប្រុសគេធ្វើកន្លែងផ្សេង ស្រីផ្សេងទៅ ។

ឈុនលី ៖ ហើយមានអ្នកនៅក្នុងភូមិទៅជាមួយមីង ស្រីៗ?

ម៉ុន ៖ ក្នុងភូមិ អត់ ។

ឈុនលី ៖ មីងម្នាក់ឯង?

ម៉ុន ៖ ចាំ! ដល់បានក្រោយមកមានគេទៅដែរ តែឥឡូវពេលគេចូលស្រុកវិញ ពេលខ្ញុំទៅលេង ខ្មាស់ មានមើលគេ ។

ឈុនលី ៖ អ្នកណាអ្នកខ្មាស់?

ម៉ុន ៖ អ្នកនៅនេះនឹង ។

ឈុនលី ៖ ម៉េចអីចឹង ម៉េចបានខ្មាស់?

ម៉ុន ៖ ខ្មាស់ដូចថាឥឡូវប្ដីក៏គេអត់យកដែរ ដែលនៅស្រុកនឹង គាត់ថាឃើញខ្ញុំទៅអត់ដែលហ៊ាន និយាយទៅ ខ្មាស់ថាទៅតស៊ូនឹងគេដែរ ដល់ពេលទីចុងបញ្ចប់មកវិញអត់មានអី ដូចខ្ញុំមក វិញមានគ្រួសារមានកូនមានចៅទៅលេងស្រុកសុខសាន្តធម្មតា ។ ដល់គាត់ចូលទៅស្រុកវិញ តែអត់មានយកប្ដីយកអីទេ ប្រជាជននៅក្នុងបេះប្រាប់ខ្ញុំថាវាខ្មាស់ ។

ឈុនលី ៖ ចុះមីងនៅក្នុងព្រៃនឹងបានប៉ុន្មានឆ្នាំនៅធ្វើពេទ្យនឹង?

ម៉ុន ៖ យូរដែរ នៅធ្វើពេទ្យនឹងបានប្រហែលម៉ាឆ្នាំ យើងមិនម៉ាឆ្នាំគត់លើសតិចតួច ដល់អីចឹងចង់ ធ្វើទ័ព ចេញមកអាពេលដែលប្អូនដែលល្បីយើងអត់ទាន់ អាពេលវ៉ៃត្រពាំងព្រាយ ថាងាប់ ពួកខ្មែរក្រហមច្រើន ។

ឈុនលី ៖ ត្រពាំងព្រាយអីគេ?

ម៉ុន ៖ អានៅជិតភ្នំពេញ ។

ឈុនលី ៖ នៅស្រុកអីគេទៅ?

ម៉ុន ៖ កំពង់ស្ពឺ ។

ឈុនលី ៖ អានឹងជាតំបន់មួយ?

ម៉ុន ៖ តំបន់មួយនៅជិតកំពង់ស្ពឺ នៅជិតចូលទីក្រុងដែរ ខ្ញុំធ្វើទ័ពៗហើយ ។

ឈុនលី ៖ មីងធ្វើទ័ពម៉េចបានទាក់ទងនឹងត្រពាំងព្រាយនឹង?

ម៉ុន ៖ កាលជិតទាន់នឹងធ្វើទៅ កាលនឹងខ្ញុំនៅខាងនារតី ហើយទ័ពដែលគេត្រូវវ៉ៃនឹងនៅខាងកំពង់ស្ពឺ ដូចថាសុំទ័ពមក ពួកខ្ញុំរៀនទ័ពបានប៉ុន្មានខែទេ ៣ខែ បេះរៀនទៅ ដូចថាអ្នកមន្ទីរដែលខ្ញុំថា ធ្វើពេទ្យនឹងគេអត់ឲ្យធ្វើទេ តែដូចថាគំនិតចង់សប្បាយនឹងគេនោះ យើងអត់ទាន់ដឹងថាងាប់ រស់ម៉េច ។

ឈុនលី ៖ អ្នកណាអត់ចង់ឲ្យមក ប្រធានមន្ទីរ?

មុ៉ន ៖ ចា៎! អត់ចង់ឲ្យមកទេ ។

ឈុនលី ៖ ប្រធានមន្ទីរនឹងស្រី ឬប្រុស?

មុ៉ន ៖ ប្រុស ។

ឈុនលី ៖ ឈ្មោះអីគេ?

មុ៉ន ៖ ឈ្មោះ តាសំបួរ ឥឡូវគាត់នៅស្រុកនោះ ។

ឈុនលី ៖ ស្រុកណាទៅ?

មុ៉ន ៖ ស្រុកអង្គស្នួលនឹង ចូលពួកដែលតស៊ូជំនាន់មុននោះ ។

ឈុនលី ៖ មានតែមីង?

មុ៉ន ៖ ចា៎! គេចូលស្រុកអត់ហើយនៅតែខ្ញុំ ។

ឈុនលី ៖ ចុះដល់ពេលចូលធ្វើទ័ពគ្នាច្រើន?

មុ៉ន ៖ ច្រើន ។

ឈុនលី ៖ ប៉ុន្មាននាក់?

មុ៉ន ៖ បើយើងនិយាយប្រហែលម៉ាកងធំ ៦០នាក់ដែរ ។

ឈុនលី ៖ អត់ដល់រយ?

មុ៉ន ៖ អត់ទេ បើម៉ាកងធំអាច១០០ ពួកដែលខ្ញុំកាន់នឹង៦០ជាងទេ ។

ឈុនលី ៖ ដល់ពេលចូលធ្វើទ័ពអ្នកណាអ្នកកាន់ទ័ព?

មុ៉ន ៖ នៅបែកចាននឹងដែរ ឈ្មោះបងរី ។

ឈុនលី ៖ ប្រុស?

មុ៉ន ៖ ស្រី ។

ឈុនលី ៖ ស្រីកាន់ទ័ព?

មុ៉ន ៖ ចា៎! កូនចិន តែខ្ញុំបានម៉ាតិចអាទ័ពនឹងបានប្រហែល២-៣ខែនឹង ។

ឈុនលី ៖ ម៉េចបានឈប់វិញ?

មុ៉ន ៖ ឈប់វិញដូចថាគិតទៅមិនទាន់ដូចនេះណា អ្នកទ័ពនឹងគេត្រូវឲ្យនៅទ័ពរហូតអត់ទេ ដល់ពេលមើលទៅគំនិតដូចថាវាមិនចង់នៅឃើញ កាលនឹងបងខ្ញុំគាត់មានរបួសក្បាល ពុកគេថាឆាប់ស្មារតីនឹងដូចថាតស៊ូទៅ ខ្ញុំនឹកឃើញថាតស៊ូយូរៗអស់បងអស់ប្អូនខ្វាច ក៏ឈប់ ។ ពេលគេចូលភ្នំពេញ ចូលនឹងគេទៅ បើថាឲ្យដូចថាខ្ញុំថាឲ្យដឹកជញ្ជូនឲ្យធ្វើស្អីៗទ័ពនឹងក៏អត់មានបានវៃដំប្រំផាក់ ទៅដឹកជញ្ជូននឹងគេទេ ។

ឈុនលី ៖ ធ្វើអី?

ម៉ុន ៖ អាទ័ពនឹង ទៅទ័ពនឹងគេនៅក្រោយ បានដឹកនាំគេម៉ាភ្លេតនឹង ។

ឈុនលី ៖ កាលនឹងគេវៃជាមួយខាងណា?

ម៉ុន ៖ គេវៃជាមួយខាងនេះទៅ ។

ឈុនលី ៖ លន់ នល់?

ម៉ុន ៖ ចា៎!

ឈុនលី ៖ វៃនៅស្រុកអីគេ?

ម៉ុន ៖ មិនស្គាល់ផងជំនាន់នឹង តែខ្ញុំគ្មានបានចូលសមរភូមិប្រយុទ្ធអីនឹងគេ គ្រាប់កាំភ្លើអីអត់ នៅបាបតិចនឹង ចេញពីនឹងមកក៏គេថា បែកភ្នំពេញហើយ ចូលទៅភ្នំពេញបណ្ដោយ ។

ឈុនលី ៖ ដល់ពេលចូលទៅភ្នំពេញនឹង នៅរបៀបម៉េចធ្វើអី?

ម៉ុន ៖ ចូលទៅភ្នំពេញដំហានដំបូងគេជ្រើសរើសខ្ញុំឲ្យទៅនៅកន្លែងពោធិ៍ចិនតុង គេហៅក្រសួងការបរទេស គេឲ្យទៅនៅនឹង ។

ឈុនលី ៖ ហើយនៅនឹងធ្វើម៉េច?

ម៉ុន ៖ ទៅនៅនឹងយើងថាធ្វើការអី តែយើងមិនទាន់បានធ្វើការណាជំនាន់នឹង នៅដេកស៊ីៗមើលទៅវាដូចស្វាត់ពេក ខ្ញុំក៏សុំចេញពីនឹងមកទៀត ។ ចេញពីនឹងមកនៅតាមកង នៅតាមមន្ទីរដែលយើងនៅគ្នាយើង ។ ដល់ពេលគេជ្រើសរើសខ្ញុំមកកាន់អង្គរវិញ ។

ឈុនលី ៖ ដល់ពេលនៅភ្នំពេញនៅជាមួយអ្នកណា បងមីងមកអត់?

ម៉ុន ៖ បងប្រុសខ្ញុំ គេវៃគ្នាអីចឹងខ្ញុំក៏រត់បែកបងប្រុសទៅ តែឥឡូវបងប្រុសចូលទៅនៅស្រុកវិញបាត់ ។

ឈុនលី ៖ ដល់ពេលមីងមកភ្នំពេញនៅជាមួយអ្នកណា អ្នកកាន់អី?

ម៉ុន ៖ កាន់កាប់នឹង ។

ឈុនលី ៖ ចា៎! អ្នកគ្រប់គ្រងខាងក្រុមរបស់មីង?

ម៉ុន ៖ បងវី ដែលខ្ញុំថា ។

ឈុនលី ៖ គាត់កាន់ទ័ពដដែល?

ម៉ុន ៖ ចា៎!

ឈុនលី ៖ ហើយនៅភ្នំពេញបានប៉ុន្មានខែ ប៉ុន្មានឆ្នាំ ចេញមកវិញទៀត?

ម៉ុន ៖ ខ្ញុំនៅយូរដែរ នៅដល់គេដែលថាយួនវៃ ។

ឈុនលី ៖ អូ! នៅដល់៧៩?

ម៉ុន ៖ ចា៎!

ឈុនលី ៖ បានន័យថាខ្ទង់៧១អីនឹង?

ម៉ុន ៖ ដែលវៃចូល ។

ឈុនលី ៖ មីងនៅភ្នំពេញ នៅជាមួយវីនឹង?

ម៉ុន ៖ ហ្នឹងហើយ តាំងពីយើងបែកធ្វើទ័ព ទៅចូលភ្នំពេញ គេហៅបានប៉ុន្មានពាឆ្នាំណា ។

ឈុនលី ៖ ធ្វើអីខ្លះនៅនឹង?

ម៉ុន ៖ ខ្ញុំនៅភ្នំពេញ នៅរោងចក្រ ។

ឈុនលី ៖ រោងចក្រអីគេ?

ម៉ុន ៖ រោងចរកត-មួយ រោងចក្រតម្បាញ ។

ឈុនលី ៖ នៅណា?

ម៉ុន ៖ នៅថ្នល់ជាតិលេខ៤ ឥឡូវរោងចក្រនឹង រោងចក្រកាត់ដេរវិញហើយ គេហៅរោងចក្រត-១ នៅជាប់ជិតពោធិ៍ចិនតុង នៅនឹងផ្លូវ ។

ឈុនលី ៖ មីងធ្វើអីគេ ធ្វើដូចកម្មករកាត់ដេរ?

ម៉ុន ៖ ខ្ញុំនៅខាងចូលរោងចក្រ ការងារច្រើនដែរ ម្តងត្បាញៗខាងគេគ្រប់គ្រងរោងចក្រគេឃើញខ្ញុំត្បាញ គេឲ្យខ្ញុំមកដឹកនាំផ្នែកខាងអន្ទង ខាងល្មីងវិញ ។ អន្ទងទាក់ទងមានគ្រល់គេសម្រាប់គេត្បាញចេះនោះ ។

ឈុនលី ៖ អន្ទងនឹងគេធ្វើម៉េច?

ម៉ុន ៖ អន្ទងគេយករបោះដុំៗដូចកង់យើងយកទៅពាក់ម៉ាស៊ីនទាញវាមក ហើយអន្ទង យើងបានជាអំបោះដុំៗហើយ យើងយកទៅពាក់ៗ យើងមូលៗចេញជាអំបោះមួយផ្ទាំង ដើម្បីចាក់នឹងធ្មេញឈើធ្វើជាសាច់ក្រណាត់ ។ ចាក់ធ្មេញឈើបានហើយតំឡើងចូលម៉ាស៊ីន ត្បាញយក ត្បាញម៉ាស៊ីន ។

ឈុនលី ៖ មីងអ្នកកាន់ខាងអន្ទងនឹង?

ម៉ុន ៖ ចា៎! ផ្នែក ។

ឈុនលី ៖ មីងមានដូរឈ្មោះដូរអី ពេលចូលមក ឈ្មោះអីចឹងរហូត?

ម៉ុន ៖ អីចឹងរហូត បងខ្ញុំគាត់អត់ឲ្យដូរ គេដាក់ឈ្មោះភ័ណ្ឌណាណៃ បងខ្ញុំគាត់ថាអត់មានធ្វើបដិវត្តដូរឈ្មោះចំណេញឈ្មោះ ។ គាត់អត់ឲ្យដូរ ឈ្មោះអីចឹងកើតមកអីចឹងបណ្តោយ ។

ឈុនលី ៖ នៅក្នុងអំឡុងពេលពាឆ្នាំនឹងនៅត្បាញ កាន់ខាងនឹងរហូត?

ម៉ុន ៖ ចា៎! នៅនឹងរហូតទាល់តែរស់ ។

ឈុនលី ៖ ចុះក្នុងអំឡុងពេលនឹង មីងមានផ្លាស់ទៅណាទៅណៃ?

ម៉ុន : អត់ ។

ឈុនលី : ចុះមានចេញទៅណាទៅណៃនឹងគេ?

ម៉ុន : អត់ នៅនឹងរោងចក្រនឹង នៅដល់គេថាវ៉ៃម៉េចទេ ជំនាន់នឹង យួនចូលស្រុក ចេញមកគេថាម៉េចជម្លៀសម៉ារយៈក៏រហូតមកបណ្ដោយ ។

ឈុនលី : ក្នុងពេលនឹងអត់ដែលជួយអ្នកណាម្នាក់នៅកន្លែងត្បាញ?

ម៉ុន : អត់មានជួយអី បើគេចាត់តាំងជាកងៗ ។

ឈុនលី : មីងកាន់កម្មករប៉ុន្មាននាក់?

ម៉ុន : ខ្ញុំកាន់កម្មករម៉ាផ្នែកនឹង ផ្នែកតម្បាញផងល្វឹងផងគ្នាច្រើនដែរ?

ឈុនលី : ២ផ្នែកត្បាញល្វឹង?

ម៉ុន : ចា៎! អានឹងជាមួយគ្នា ចន្លោមចាក់ធ្មេញឈើ ត្បាញៗអត់ទេ ចាក់ធ្មេញឈើ អន្ទង និងល្វឹង គេធ្វើខ្នាតចេះនឹងគេហៅល្វឹង ធ្វើអានឹង៣ផ្នែក ។ ម៉ាវេណៗចូលទៅគ្នាប្រហែល៣០ ៤០នាក់ ។

ឈុនលី : អ្នកនៅត្បាញ អ្នកកម្មករ?

ម៉ុន : វេណអ្នកកម្មករដែលយើងត្រូវដូរ តែបើគិតជាក្នុងម៉ាបរិវេណដែលគ្រប់គ្រងវាច្រើនដែរ ចុះវាដូរវិលជុំ ។ ដូចខ្ញុំធ្វើម៉ោង៧ចេញម៉ោង១២ មានគេដូរខ្ញុំម៉ោងពីម៉ោង១២ដល់ម៉ោង៥ មានម៉ោង៥ដូរវិលជុំ ។

ឈុនលី : បានន័យថារោងចក្រនឹងធ្វើការវាស់ព្រឹក?

ម៉ុន : អត់ ទាល់វិល ទាំងត្បាញ ។

ឈុនលី : ចុះកម្មករគេមានដាក់វេណដែរ?

ម៉ុន : ចា៎! ហ្នឹងហើយវេណអីចឹងវិលរហូត ។

ឈុនលី : ចុះអ្នកដែលគ្រប់គ្រងដូចមីងមានប៉ុន្មាននាក់?

ម៉ុន : មានម៉ាផ្នែកមាន៣នាក់ ផ្នែកត្បាញមាន៣ ផ្នែកអន្ទងមាន៣ ។

ឈុនលី : ចុះអ្នកដែលគ្រប់គ្រងនឹងមាន៩នាក់ បើមានតែ៣ផ្នែក?

ម៉ុន : ចា៎!មានសាខា មានដូចថាអ្នកល្វឹងមាន៣នាក់ អ្នកខ្នាមាន៣ ដូចយើងថាមកមេៗ បើយើងនិយាយតាមកង ដូចថាកងវរៈគេកាន់កូនបន្ទាប់មកកងអនុសេនាធំ អនុសេនាតូច របៀបអីចឹង អានឹងតាមផ្នែកដូចថា អន្ទងនឹង មានម៉ាស៊ីន៣០នាក់វាមាន៣នាក់ទៀតអ្នកគ្រប់គ្រងនៅក្នុងល្វឹងនឹង ដល់ពេលអន្ទងនឹងមានក្រុមអន្ទងនឹងមាន៣នាក់ទៀតទៅ ។ ដល់សរុបរួមមានពួកខ្ញុំ៣ពីលើទៅ ។

ឈុនលី ៖ បើគិតទៅកម្មករនឹងច្រើននាក់?

ម៉ុន ៖ ច្រើន កម្មករឡើងចូលពាន់ហើយម៉ារោងចក្រនឹង ។

ឈុនលី ៖ មានប្រជុំមានអីនៅក្នុងរោងចក្រ?

ម៉ុន ៖ ប្រជុំ ។

ឈុនលី ៖ អ្នកណាអ្នកដឹកនាំប្រជុំ?

ម៉ុន ៖ ដឹកនាំប្រជុំមានមេទៀតដូចខ្ញុំថា មានមេ៣នាក់ទៀតទៅ ។

ឈុនលី ៖ ដុត៣នាក់នឹងអស់ហើយ?

ម៉ុន ៖ ដុត៣នាក់នឹងអស់ហើយ បាទមកពួកខ្ញុំ ។

ឈុនលី ៖ ៣នាក់នឹងមានស្រីមានប្រុស?

ម៉ុន ៖ ចាំ!

ឈុនលី ៖ មីងចាំឈ្មោះគាត់?

ម៉ុន ៖ ភ្លេចអស់ហើយ បើនោះអាចចាំខ្លះៗ ។

ឈុនលី ៖ អ្នកណាគេ?

ម៉ុន ៖ គាត់នៅជាមួយនេះដែរ ។

ឈុនលី ៖ មីងដូះនេះ?

ម៉ុន ៖ អឺ!

ឈុនលី ៖ មីងដូះនេះ?

ម៉ុន ៖ ចាំ!

ឈុនលី ៖ ស្គាល់គាត់តាំងពីដើមមក?

ម៉ុន ៖ ចាំ! តាំងពីនៅលីវៗ ។

ឈុនលី ៖ តែគាត់អត់មានកាន់ខាងអី គាត់ធ្វើ?

ម៉ុន ៖ ចាំ! គាត់កាន់ដែរ ខាងតម្បាញ ក្រុមតម្បាញ តែតម្បាញច្រើន បច្ចេកទេស ដូចខ្ញុំថា ដូចក្រុមត្បាញ អន្ទង លុីងដូចគ្នា ។ តែគ្រាន់រោងចក្រខ្ញុំ ម៉ាជំនាន់នឹងរោងចក្រដទៃទៀត គេដកហើយ គេចាប់ផ្តើមដកពុក្សសួរថាទៅនេះទៅនោះស្អីៗណា ។

ឈុនលី ៖ គេដកពីខាងណា?

ម៉ុន ៖ ជំនាន់នោះ ខ្ញុំអត់ដឹងដែរ បើដូចខ្ញុំថា មករោងចក្រខ្ញុំអត់ទាន់មានដកអីណា ។

ឈុនលី ៖ យើងអត់ដឹង?

ម៉ុន ៖ ចា៎! អត់ដឹងទេ អត់ទាន់មានដកទេ បើថានៅតិចទៀតអាចមានដោយខ្លះ តែដល់ពេលពួកខ្ញុំមកនឹងអត់ទាន់មានដោយ ។ ដល់មកខ្ញុំមកជាប់បានឈ្មោះយាយស្រួន អានឹងដឹងនាំ គាត់ខាងអនុ ។

ឈុនលី ៖ អនុអីគេ?

ម៉ុន ៖ អនុប្រធានរោងចក្រនឹង ឈ្មោះ យាយស្រួន ស្រី ។

ឈុនលី ៖ គាត់កាចទេ?

ម៉ុន ៖ អត់អីដឹកនាំពួកខ្ញុំមករហូត ។

ឈុនលី ៖ ចុះដូចអ្នកដែលមានឋានៈស្មើមីងមានស្រីមានប្រុស?

ម៉ុន ៖ ពួកខ្ញុំមានតែស្រីៗ ។

ឈុនលី ៖ ស្រីសុទ្ធ?

ម៉ុន ៖ ចា៎!

ឈុនលី ៖ ចុះកម្មករក្នុងរោងចក្រនឹង សុទ្ធតែស្រី?

ម៉ុន ៖ ប្រុសប្រមាណប្រហែល៥០-៦០នាក់ប៉ុននឹងសម្រាលធ្វើម៉ាស៊ីន ដូចថាម៉ាស៊ីនខូច យើងវៃផ្ទាកនឹង គេឃើញផ្ទាកនឹង គេមកធ្វើ ។

ឈុនលី ៖ ចុះអ្នកប្រុសនឹងសុទ្ធតែជាង?

ម៉ុន ៖ សុទ្ធតែជាង ។

ឈុនលី ៖ កម្មករសុទ្ធតែស្រី?

ម៉ុន ៖ ចា៎! ស្រី... ដូចអត់មានដែលទំនាស់ប្រដែកស្អី ឬយើងនិយាយសម័យឥឡូវវៃដំនៅក្នុងរោងចក្រអីអត់ ។

ឈុនលី ៖ ការហូបចុកម៉េចទៅ?

ម៉ុន ៖ ការហូបចុក បើជំនាន់ដែលយើងអត់មានអង្ករ យើងហូបនំប៉័ង ។

ឈុនលី ៖ អត់បបរ?

ម៉ុន ៖ ចា៎! ហូបនំប៉័ង ស្ងម្ពរស្ងអីដូចតែយើងហូបជាមួយបាយ ។

ឈុនលី ៖ តែអត់ហូបបបរទេ មានតែបាយហើយនឹងនំប៉័ង?

ម៉ុន ៖ ចា៎!

ឈុនលី ៖ មីងធ្វើការខាងក្នុងនឹង ដែលឮខាងក្រៅអត់បាយ?

ម៉ុន ៖ ឬតែនៅភ្នំពេញ ឮថាអត់បាយ យើងហូបនំប៉័ង ។

ឈុនលី ៖ ចុះក្នុងអំឡុងពាឆ្នាំ ភ្នំពេញគេជម្លៀសប្រជាជនចេញអស់?

មុំន ៖ ជម្លៀសអានៅក្នុងឆ្នាំប៉ុន្មាន ។

ឈុនលី ៖ ៧៥ គេជម្លៀសប្រជាជន?

មុំន ៖ ជម្លៀសមកដូចខ្ញុំថា ជម្លៀសមកគេថាគ្រាន់ជម្លៀសម៉ាំរយៈ ។

ឈុនលី ៖ អត់ទេ អានឹង៧៩ អាពេលវៀតណាមចូលហើយបានគេថាជម្លៀសម៉ាំរយៈ?

មុំន ៖ ជម្លៀសម៉ាំរយៈ ចេញមករហូតបណ្តោយ ។

ឈុនលី ៖ ចុះដូចមីង?

មុំន ៖ ចា៎! អានឹងចេញពីរោងចក្រមកលើ ។

ឈុនលី ៖ អានឹង៧៩ ពេលវៀតណាមចូល?

មុំន ៖ ហ្នឹងហើយគេថាវៀតណាមចូល ។

ឈុនលី ៖ ខ្ញុំចង់សួរថាពេលខ្មែរក្រហមចូលដល់ភ្នំពេញដំបូង អានឹងឆ្នាំ១៩៧៥?

មុំន ៖ អានឹងខ្ញុំនៅ ខ្មែរក្រហមយើងនៅពួកខ្ញុំទើបនឹងចូលបណ្តោយ ។

ឈុនលី ៖ ធ្វើការរោងចក្រ?

មុំន ៖ ហ្នឹងហើយ ដែលធ្វើការរោងចក្រចាប់ផ្តើមយើងខ្មែរក្រហមចូលទៅនៅកាន់កាប់នឹង ។

ឈុនលី ៖ ខ្ញុំចង់សួរថាពេលនឹង ពេលនឹងគេជម្លៀសប្រជាជនចេញអស់ពីទីក្រុងហើយឬនៅ?

មុំន ៖ ចា៎! ជម្លៀស ។

ឈុនលី ៖ នៅសល់តែគ្នាយើងអ្នកធ្វើ?

មុំន ៖ ចា៎! នៅសល់តែពួកខ្ញុំដែលអ្នកដូចថាចូលរួមតស៊ូនៅនេះទេ ប្រជាជននឹងអត់ដឹងជម្លៀស តាំងពីស្មានម៉ាន អត់ដឹងទេ អត់ឃើញទេពួកខ្ញុំ ។

ឈុនលី ៖ ស្ងាត់?

មុំន ៖ ចា៎! ពួកខ្ញុំចូលទៅស្ងាត់ម៉ង ។

ឈុនលី ៖ មីងភ័យអត់ ខ្លាចអត់បើស្ងាត់?

មុំន ៖ ចុះបើយើងធ្លាប់តស៊ូនៅនឹងព្រៃអត់មានខ្លាចអី ។

ឈុនលី ៖ ហើយអារឿងខាងក្រៅ យើងអត់ដឹង យើងគិតតែធ្វើការ?

មុំន ៖ អត់យើងអត់ដឹងជំនាន់នឹង អ្នកណាដូចថា ដូចយើងនិយាយអ្នកណាធ្វើធំ អ្នកណាធ្វើតូច យើងជំនាន់នឹង ដូចអត់មានបច្ចេកទេសនិយាយចេះតវ៉ាអី បើថាប្រជុំមានតិតៀន្គ្នារឿង សីលធម៌ កុំកាច កុំនិយាយប្រលើមបើស កុំអីត្រូវអោនលំទោនដាក់ប្រជាជន ត្រូវឃើញ ប្រជាជនក្រីក្រយើងដើរទៅឃើញត្រូវចេះជួយមានណែនាំចេះឯង ។

ឈុនលី ៖ ចុះពេលវៀតណាមចូល?

ម៉ុន ៖ ពេលវៀតណាមចូលខ្ញុំចេញបាត់ ។

ឈុនលី ៖ មួយទៀតពេលអំឡុងពេលរោងចក្រនឹងដែលមានថ្នាក់ដឹកនាំណាធំៗគេទៅមើលទេ?

ម៉ុន ៖ មានតើ ។

ឈុនលី ៖ ខាងអ្នកណាគេ?

ម៉ុន ៖ ពួកមកពីក្រៅៗអី យើងអត់សូវដឹងដែរ តែជួនកាលគេទៅទស្សនកិច្ចអានឹងយើងចាប់ផ្តើមពាក់ឯកសណ្ឋាន ។

ឈុនលី ៖ ទាល់តែពេលគេទៅបានពាក់?

ម៉ុន ៖ អត់ទេរោងចក្រខ្ញុំគេពាក់អាវបែបខ្វី ។

ឈុនលី ៖ សខ្មៅ?

ម៉ុន ៖ អត់ខ្មៅ ពណ៌ខៀវ ។

ឈុនលី ៖ អ្នកធ្វើការរោងចក្រអត់ពាក់អាវខ្មៅទេ?

ម៉ុន ៖ អត់ទេ អាវខ្មៅនឹងទាល់តែទំនៀមទំលាប់ធម្មតា អ្នកខ្លះគេខ្ជិលគេមានអាវខ្មៅ គេពាក់ទៅខ្លះគេអាវពណ៌ខៀវត្រឹមៗ ។

ឈុនលី ៖ ស្លៀកខោ ស្លៀកសារុង រោងចក្រ?

ម៉ុន ៖ រោងចក្រស្លៀកខោ ស្លៀកសំពត់ខ្មៅ តាមអ្នកចំណូលចិត្ត ស្លៀកសំពត់ស្លៀកខោៗ ។

ឈុនលី ៖ បើគេហៅរោងចក្រអីគេ?

ម៉ុន ៖ គេហៅគ-១ ។

ឈុនលី ៖ ចុះថ្នាក់ដឹកនាំគេមានតែអ្នកបរទេសដែលមក?

ម៉ុន ៖ ទេ! ថ្នាក់ដឹកនាំនៅក្នុងនឹងអត់ទេ គ្រាន់តែគេមកទស្សនកិច្ចអី ។

ឈុនលី ៖ ចុះដូចថ្នាក់ដឹកនាំខ្មែរយើងធំៗ?

ម៉ុន ៖ ខ្មែរយើងធំៗមានតែអ៊ីៗគាត់ចូលម៉ាភ្លែតចេះនាំគណប្រតិភូមិទៅ ។

ឈុនលី ៖ អ៊ីណា?

ម៉ុន ៖ តាវ៉ន វេត ស្ពឺមួយទៀតបន្ទាប់តាវ៉ន វេត តាខៀវ សំផន ។

ឈុនលី ៖ ដែលឃើញគាត់ ឃើញផ្ទាល់?

ម៉ុន ៖ ឃើញ បើយើងទោះបីមិននៅអីចឹងឃើញជាមួយគាត់ ខ្ញុំនៅមន្ទីរជាមួយ ។

ឈុនលី ៖ ប៉ុន្តែការនៅនឹងទើបនឹងស្គាល់?

ម៉ុន ៖ ចា៎! ខ្ញុំទើបស្គាល់ដូចថាក្រសួងតានេះគ្រប់គ្រង តានោះគ្រប់គ្រង យើងស្គាល់តាមអីចឹងហៅទៅរៀនទៅសូត្រ ។

ឈុនលី ៖ កាលនឹងអ៊ំខៀវ សំផននឹងគាត់ធ្វើខាងអីទេ?

ម៉ុន ៖ គាត់ខាងក្រសួង ។

ឈុនលី ៖ ប្រមុខរដ្ឋ? អត់សូវដឹងដែរ?

ម៉ុន ៖ អត់សូវដឹង ៗ អ្នកធំៗ គេគ្រប់គ្រងផ្នែកអីមួយៗ យើងអត់សូវដឹង ។

ឈុនលី ៖ ចុះតាអៀង សារីនៅនោះ?

ម៉ុន ៖ តាអៀង សារីដឹងថាគាត់ផ្នែកក្រសួងការបរទេស ។

ឈុនលី ៖ ចុះប្រពន្ធគាត់អី?

ម៉ុន ៖ ប្រពន្ធគាត់ក៏ខ្ញុំមិនសូវដឹងដែរ ការងារគាត់បែកផ្នែកម៉េចអត់សូវដឹង ។

ឈុនលី ៖ ចុះកាលមីងធ្វើពេទ្យនឹង អត់ទាន់ក្នុងអំឡុងឆ្នាំនឹងដដែល?

ម៉ុន ៖ នៅ អានឹងយើងមក នៅចូលព្រៃនៅឡើយ ។

ឈុនលី ៖ ហើយដល់ពេលដែលបែក ពេលវៀតណាមចូលគេប្រាប់ម៉េច ហើយបាននាំគ្នាចេញ?

ម៉ុន ៖ ហ្នឹងហើយបានគេថាជម្លៀសសភាពការណ៍មិនស្រួលទេ ។ ហើយបើនេះនឹងត្រៀមខោអាវ ត្រៀមកាំបិតត្រៀមចបត្រៀមអីនឹងដើម្បីយើង ។

ឈុនលី ៖ អានឹងឆ្នាំ៧៨ ឬ៧៩?

ម៉ុន ៖ ឆ្នាំ៧៩ដឹង ដែលយើងរត់មក?

ឈុនលី ៖ អាចថាចុង៧៨ ឬក៏ចូល៧៩ហើយ?

ម៉ុន ៖ អីចឹងបានថាខ្ញុំមិនសូវចាប់អារម្មណ៍រឿងអីចឹង ៗ ឥឡូវក៏មិនសូវចាំទៀត ចាំដំណើរធ្វើអីត ៗ មកយើងចេះនឹកឃើញចង់បាន ។

ឈុនលី ៖ ដល់ពេលវៀតណាមចូលគេប្រាប់ ប្រកាសម៉ង?

ម៉ុន ៖ ចា៎!

ឈុនលី ៖ ថាម៉េច?

ម៉ុន ៖ ប្រធានមីង គណៈរោងចក្រមកប្រាប់ ថាឥឡូវយើងសភាពអត់ស្រួលទេ យើងដកចេញៗ មក ។ ចុះតែគេឲ្យដកចេះដកប្រុស ៗ ទៅ តែរឿងហេតុផលអីយ៉ាងម៉េចអត់ដឹងទេ ឮថាយួនចូលស្រុក ៗ ដល់មកតាមផ្លូវអីចឹងមកដើរ ៗ ឃើញរថក្រោះ តែអត់ទាន់មានបានបាញ់គ្នាអីទេ ។

ឈុនលី ៖ ពេលមកម៉ារោងចក្រ?

ម៉ុន ៖ មកតាមរោងចក្រ មុនដំបូងខាងគេមកមុនខ្ញុំ ខ្ញុំមកក្រោយ រោងចក្រខ្ញុំចេញក្រោយគេចេះតែឆ្ងល់ ហើយពួកខ្ញុំចេះដឹកអំបោះតាមរោងចក្រត្បាញណា ។ យើងចេះឆ្ងល់ថា ម៉េចគេ

មិនដឹកអំបោះ ចុះគេជម្លៀសទៅ អាខ្លះជម្លៀសទៅតាមរទេះភ្លើងចេះដិះ ។ ពួកខ្ញុំគ្មានណា ពួកនឹងចេញមក ចេញល្ងាចទៀត គេថាឥឡូវត្រូវដកចេញពីរោងចក្រម៉ារយៈទៅនៅមក លិច ។ ចេះមកលិចមក ដើរនៅតាមភូមិតាមអីនឹង ដើរមករហូត ។ មុនដំបូងថាយើងដើរ ទៅជិះរទេះភ្លើង ទៅរទេះភ្លើងចាំបាត់ៗ ។ បើយើងនិយាយថា ពួកផ្ដែកក្នុងគេណា ធ្វើ របៀបថាផ្អាកដំណើរមិនឲ្យយើង ។

ឈុនលី : ករយើង?

ម៉ុន : ចា៎! របៀបករយើង អានឹងយើងនិយាយតាមដំណើរដែលយើងដឹង ។ ដល់ពេលនឹងគ្មាន បានជិះអី ។

ឈុនលី : ដើរមករហូត?

ម៉ុន : ដើរមករហូត ។

ឈុនលី : ម៉ារោងចក្រមកជាមួយគ្នាមករហូត?

ម៉ុន : មកជាមួយគ្នា ចេះរអូករអឺន ដឹកនាំតាមកងតាមអីមករហូត ។

ឈុនលី : ដើរតាមផ្លូវកាត់ពោធិ៍សាត់ បាត់ដំបង?

ម៉ុន : ចា៎! ចេះដើរទៅ ។

ឈុនលី : អត់សម្រាកទេ?

ម៉ុន : ទេ! ដល់ពេលអត់អីចឹងសម្រាកមើលបានម៉ាតិច គេថារៀបមិនស្រួលមកទៀតហើយ តែ មិនដឹងមកអីទេ ទៅទៀតទៅ ។

ឈុនលី : បានអីហូបតាមផ្លូវ?

ម៉ុន : ហូបមានបាយមានអីធម្មតា ។

ឈុនលី : ឈប់ត្រង់ណាដាំត្រង់នឹង?

ម៉ុន : ចា៎! ឈប់ត្រង់ណា ។

ឈុនលី : មានគេចែកអង្ករឲ្យយើង?

ម៉ុន : ចុះខាងអ្នកដឹកនាំ គេមានមកអីចឹងមក ។

ឈុនលី : គេមានបាយឲ្យហូប?

ម៉ុន : ចា៎! គេមកអីចឹងមក ។

ឈុនលី : ប្រហែលប៉ុន្មាន បើប៉ាន់ស្មាន?

ម៉ុន : ច្រើនរោងចក្រខ្ញុំ ជិតម៉ាពាន់ ។

ឈុនលី : ហើយអ្នកផ្សេងទៀត?

មុ៉ន : អ្នកផ្សេងទៀតមិនដឹងប៉ុន្មានរាប់រយរាប់ម៉ឺន ។

ឈុនលី : ចុះអ្នកដែលមកមុន មីងមកទាន់គេ?

មុ៉ន : មកទាន់គេមកជាប់តាមផ្លូវ ជួនកាលដាច់ដោចទៅអត់ទាន់គេ អាខ្លះគេបែកទៅស្រុកទៅអីវិញ ។

ឈុនលី : លួចចេញមកស្រុក?

មុ៉ន : ចា៎! បើខ្ញុំត្រូវមកស្រុក ទៅ ។

ឈុនលី : ចុះហេតុអីបានមីងអត់មក?

មុ៉ន : អាណិតគេ ។

ឈុនលី : អាណិតអ្នកណាគេ?

មុ៉ន : អាណិតដែលយើងធ្លាប់ដឹកនាំគេ នឹកឃើញអីចឹង ចុះគេអត់ទៅណាបងលិច បងកើតជំនាន់នឹងចេះអីចឹង យើងមិនមានអីអត់ដែលឈ្លោះគ្នា មិនដែលអីដូចថានឹកឃើញអាណិតដូចបងដូចប្អូន ។ ចុះបើខ្ញុំមកដើរតាមនឹងចុះពីថ្នល់ជាតិតិចដល់ផ្ទះៗមើលក្បឿងក្រហម នៅនឹងផ្លូវ កាលជំនាន់នឹងផ្ទះខ្ញុំខ្ទេចអស់ហើយ ទើបលើកជំនាន់ថ្មីៗនេះ ។

ឈុនលី : ដើរកាត់ផ្ទះឯងដែរ?

មុ៉ន : ដើរជាប់នឹង ។

ឈុនលី : អត់ព្រមចូលផ្ទះ?

មុ៉ន : អត់ ។

ឈុនលី : ហើយមកនៅដំបូងនៅប៉ែកខាងលិច?

មុ៉ន : ប៉ែកខាងលិចដំបូងបង្អស់ អានឹងអត់ទៀងអត់ទាត់ មកដល់នឹងបណ្ដោយចុះយើងដើរដំណាក់ដល់ពេលទិសដៅមកកំណត់នឹងម៉ង ។

ឈុនលី : អ្នកណាអ្នកដឹកនាំដើរមករហូត?

មុ៉ន : ដែលខ្ញុំមកនឹង បើនិយាយរកអ្នកដឹកនាំ រកសឹងមិនឃើញ ចេះមកតាមៗគ្នា យើងថាមានអ្នកដឹកនាំដែរ តែចេះមកៗ ។ ដូចខ្ញុំមកនិយាយប្រាប់មុន មកដល់សាយសាម៉ន បានគេជ្រើសរើសខ្ញុំមកទៀត គេជ្រើសរើសខ្ញុំចេញពីកងវរៈនឹងហើយ ។ អានឹងគេចាត់តាំងជាកងហើយ តែអត់មានជាកងវរៃដំប្រំធាក់អីទេ ។

ឈុនលី : កងរស់នៅ?

មុ៉ន : កងរស់នៅដូចថាជាក្រុមៗស្រណុកបាត់គ្នាយើងដឹង ដល់មកអីចឹងខ្ញុំចេញពីកងវរៈនឹងឯងមកនៅ ។

ឈុនលី ៖ កងវរៈនៅណា?

ម៉ុន ៖ គេហៅគ្រប់គ្រងកងវរៈម៉ាវរៈៗ ។

ឈុនលី ៖ ឋានះស្មើអី?

ម៉ុន ៖ វរសេនាតូចស្មើនឹងស្អីទៅ អាកងធំនោះផ្សេង វរៈនោះផ្សេង ។

ឈុនលី ៖ អានឹងកាន់ខាងទ័ព?

ម៉ុន ៖ ចា៎!

ឈុនលី ៖ អានឹងហៅតាម វរសេនាតូច វរសេនាធំ?

ម៉ុន ៖ ហ្អឹងហើយ អានឹងអត់មានកាន់ខាងទ័ពអីទេ យើងហៅអីចឹងដើម្បីមកយើងមកដូចខ្ញុំថាយើងកាន់កាប់ដឹកនាំគ្នា កុំឲ្យវាដាច់បាយដាច់ទឹកឲ្យវាមានកងជាក្រុម ។

ឈុនលី ៖ ចុះមកនៅទឹកដីម៉ាឡៃ?

ម៉ុន ៖ ដល់មកនៅទៅ ខ្ញុំមកដល់គាគង់ ខ្ញុំមកដល់សាយសាម៉ន ។

ឈុនលី ៖ សាយសាម៉ននឹងស្អីគេ?

ម៉ុន ៖ ភូមិសាយសាម៉ន ។

ឈុនលី ៖ អានឹងឃុំអីគេ?

ម៉ុន ៖ ប៉ុនឃុំអី ឥឡូវឃុំគាគង់ ។

ឈុនលី ៖ មកឈប់នៅនឹង?

ម៉ុន ៖ ចា៎! ឈប់ម៉ារយៈនៅនឹង នៅប្រមូលផលៗអត់ទាន់បានម៉ាអាទិត្យ គេថាសភាពអត់ស្រួលទេ ចេញមកៗដល់តាមផ្លូវគេរើសខ្ញុំមកនៅក្រសួងការបរទេសទៀត ។ គេរើសចេញពីកងគេហៅបើយើងនិយាយចេញពីកម្មករនឹង មកនៅក្រសួងការបរទេស ។

ឈុនលី ៖ ក្រសួងការបរទេសនៅណា?

ម៉ុន ៖ ក្រសួងការបរទេសវាបែកជាក្រុមៗយើងរត់ វាអត់ទាន់ប្រមូលផ្តុំគ្នាទេ ។

ឈុនលី ៖ តែគេបង្កើត?

ម៉ុន ៖ គេមិនបង្កើតទេ ដូចថាក្រសួងការបរទេសមកពីភ្នំពេញមកៗ គេជ្រើសរើសដើម្បីឲ្យពួកខ្ញុំមកចុះជាប់ជាមួយប្រជាជន មើលប្រជាជនជួយប្រជាជន ។

ឈុនលី ៖ អីចឹងគេហៅយើងឋានះអីគេ?

ម៉ុន ៖ ឋានះនឹង អានឹងរឿងធម្មតា តែគ្រាន់ថាយើងឈ្មោះដូចយើងដឹកនាំប្រជាជនដែរ ថាឥឡូវសភាពមិនស្រួលទេ ទៅប្រាប់ប្រជាជនឲ្យនឹងនាំគ្នាទៅបរទេសគោចេញមក ។

ឈុនលី ៖ អានឹងមេកងមេក្រុម?

ម៉ុន ៖ មិនដឹងម៉េច តែគាត់ឲ្យមកនឹងអីចឹង ។

ឈុនលី ៖ តែខាងក្រសួងអ្នកចាត់ចែង?

ម៉ុន ៖ ចាស! ក្រសួងអ្នកចាត់ចែង ។

ឈុនលី ៖ អ្នកណាអ្នករើស?

ម៉ុន ៖ នេះ ឈ្មោះមាស សែៗ ។

ឈុនលី ៖ ឋានៈគាត់អីគេ?

ម៉ុន ៖ គាត់ខាងក្រសួងការបរទេស ក្រោយមកនេះ គាត់មកដល់ព្រំដែន គាត់ខាងទៅថៃ ខាងទូត ថៃ ។

ឈុនលី ៖ ឆ្នាំណា?

ម៉ុន ៖ ឆ្នាំប៉ុន្មានទេ ។

ឈុនលី ៖ គាត់តួនាទីធំអីដែរ?

ម៉ុន ៖ ធំ ។

ឈុនលី ៖ ត្រកូលអីគេ សែ?

ម៉ុន ៖ អត់ចាំត្រកូលគាត់ ។

ឈុនលី ៖ មឹងនៅគ្រប់គ្រង បានដុះអីនៅ?

ម៉ុន ៖ ដែលមកនៅតាមប្រជាជន ពេលដែលមកនៅដូចថាប្រជាជនមានប៉ុន្មាន១០០-២០០ គ្រួសារពួកខ្ញុំមានគ្នាម៉ាក្រុម៨-១០នាក់ ។ ប្រជាជនបោះទីតាំងនៅកន្លែងណាទៅ យើងទៅនៅកន្លែងនឹងដែរ ។

ឈុនលី ៖ បោះទីតាំងនៅម៉េចទៅ បើអត់មានអីចឹង? មឹងឈ្មោះអីគេហែម ដែលហៅធ្វើការប្រជាជន?

ម៉ុន ៖ មិញនឹង មិនមែនហែមទេ ។

ឈុនលី ៖ ដែលថាទៅធ្វើទូតនៅថៃ ក្រសួងបរទេស?

ម៉ុន ៖ មឹងសែ ។

ឈុនលី ៖ ចុះបន្ទាប់ពីនឹងទៀត ហើយនៅគ្រប់គ្រងនឹងអីចឹង?

ម៉ុន ៖ ចាស! គ្រប់គ្រងអីចឹងទៅ ដល់ក្រោយមប្រជាជនបែកបាក់ទៅ ពួកខ្ញុំមកតាមក្រុមនឹងវិញមក មករហូតមកនៅ មកនៅជាមួយពូរ័ត្ន គាត់ស្លាប់នៅភ្នំពេញប៉ុន្មានខែមុន ស្គាល់នេះអត់ ល្បីណាស់កាលនឹង ។

ឈុនលី ៖ ឈ្មោះអីគេ រ័ត្ន?

ម៉ុន ៖ គាត់នៅនោះដឹងគាត់ផ្លាស់ឈ្មោះអី តែអ៊ំវ័ន្តនឹង គាត់នៅក្រសួងការបរទេសនៅប្រទេសកូរ៉េ គាត់ចេញពីកូរ៉េមក គាត់មកនៅតាមព្រំដែនដឹកនាំប្រជាជនដូចខ្ញុំថាមិញ គាត់មើលប្រជាជនទៅ ។ ដល់ពេលនឹង ខ្ញុំលែងនៅមិញនៅធ្វើពេទ្យ គាត់មិនដែលស្គាល់ ។

ឈុនលី ៖ ឆ្នាំណា ចូល៨០ នៅ?

ម៉ុន ៖ ពេទ្យនឹងជំនាន់យើងវត់មក៧៩ ។

ឈុនលី ៖ ចុះតាវ័ន្តនឹង តួនាទីគាត់អីគេ?

ម៉ុន ៖ តួនាទីដឹងខាងស្អី បើគាត់ដឹងនាំប្រជាជន ដើរធ្វើការតាមប្រជាជន ពេលប្រជាជនអត់មានសំណើរតាមក្រសួងមន្ទីរសុំជូនទៅ ដូចជាថ្នាំពេទ្យ ហើយពួកខ្ញុំដើរជាមួយគាត់ ។

ឈុនលី ៖ គាត់កាន់ខាងថ្នាំពេទ្យ?

ម៉ុន ៖ អត់កាន់ខាងថ្នាំពេទ្យទេ គាត់ឃើញប្រជាជនឈឺច្រើន គាត់ស្រែកថ្នាំពេទ្យ ឃើញប្រជាជនអត់សំលៀកបំពាក់ គាត់ស្រែកថាឥឡូវប្រជាជនត្រង់នេះអត់មានសំលៀកបំពាក់ ជូនក្រណាត់អីឲ្យគាត់ទៅ ។

ឈុនលី ៖ អានឹងនៅតំបន់ណា មកដល់?

ម៉ុន ៖ នៅនឹងតាមព្រំដែន ។

ឈុនលី ៖ មានស្រុកមានអី?

ម៉ុន ៖ អត់ទាន់គ្មានស្រុកទេ មានកន្លែងគេហៅមន្ទីរនេះមន្ទីរនោះ ។

ឈុនលី ៖ មន្ទីរអីគេ?

ម៉ុន ៖ អីចឹងទៅគេហៅគីឡូ១២ ចក្រី កន្លែងនេះ ។

ឈុនលី ៖ តាវ័ន្តដូចគាត់កាន់មន្ទីរ?

ម៉ុន ៖ ដឹងកាន់មន្ទីរ មិនដឹងកាន់ស្អី ខ្ញុំចេះដើរទៅ ថាហ៎! ទៅធ្វើការជំនាន់នោះ គេមិនសូវបើកចំហរអ្នកដឹកនាំឲ្យយើង ។

ឈុនលី ៖ អ្នកធម្មតាអត់ដឹង?

ម៉ុន ៖ មិនបានដឹងតួនាទីអីគេច្រើនលាក់ការណ៍ ឧទាហរណ៍ថាទៅជួបកន្លែងតាកន១ នៅ៣២ទៅចេះដើរជ្រលងព្រៃគ្មានផ្ទះប្រជាជនទេ ។

ឈុនលី ៖ ចុះប្រជាជនដែលមកនឹងបានអីនៅ?

ម៉ុន ៖ ប្រជាជនដែលមកនឹង គាត់ចេះបោះតង់បោះអីនៅតាមអូរៗកន្លែងណាដែលមានទឹក មានអីប្រជាជននៅតាម ។

ឈុនលី ៖ មឹងថាចូលធ្វើពេទ្យ?

មុំន ៖ ចា៎!ដល់ពេលក្រោយមក ដែលខ្ញុំថាចេញពីសែនឹង ធ្វើពេទ្យជាមួយតារ័ត្ននឹង ដើរតាមគាត់រហូត ។

ឈុនលី ៖ ដល់ពេលណា?

មុំន ៖ ដើរទៅ មិនបានម៉ានឆ្នាំទេ ក្នុងឆ្នាំនឹងដែរ ដល់ពេលដើរមកៗនៅនឹងយើងបណ្តោយបោះទីតាំងនៅនឹង ។

ឈុនលី ៖ តែអត់ទាន់មានឈ្មោះម៉ាឡៃ?

មុំន ៖ អត់ទេ គាត់ក៏ចេញពីកន្លែងនឹងទៅនៅខាងខត្តរទៀត ។

ឈុនលី ៖ ទិសនៅប៉ែកខត្តរ?

មុំន ៖ នៅភ្នំដងរែក ។

ឈុនលី ៖ ពេលមីងមកគេហៅ នៅនេះអត់ទាន់មានឈ្មោះស្រុកអី?

មុំន ៖ អត់ ។

ឈុនលី ៖ គេហៅតំបន់អី?

មុំន ៖ នៅគេហៅចំការគោសោៗ គេហៅភូមិដូងៗអីចឹង ។

ឈុនលី ៖ ហើយសុទ្ធតែព្រៃ?

មុំន ៖ សុទ្ធតែព្រៃ ។

ឈុនលី ៖ មានមីននៅពេលនឹង?

មុំន ៖ នេះតាមអស់នេះ ។

ឈុនលី ៖ មីននឹងគេដាក់តាំងពីឆ្នាំណា?

មុំន ៖ អាជំនាន់ណាដែលយើងរត់ ។ ៨០ ៨១ ។

ឈុនលី ៖ ៨០ ៨១ អានឹងខាងណាអ្នកដាក់?

មុំន ៖ យើងរត់ទៅអីចឹងមិនដឹងខាងខ្មែរក្រហម មិនដឹងជាខាងអត់ដឹង ។

ឈុនលី ៖ ចុះពេលដែលមីងមកនៅ ពេលរត់មកភ្លាមអត់ទាន់មានមីនទេ?

មុំន ៖ អត់មានមីនទេ ។

ឈុនលី ៖ ដល់ពេលយើងមកនៅហើយ បានមានគេដាក់តាមក្រោយ?

មុំន ៖ ដល់ពេលយើងនៅហើយ គេថាសភាពការណ៍មិនស្រួលយើងរត់ទៅនៅដីថៃ ទៅនៅស្រុកថៃ ។

ឈុនលី ៖ នៅបានធ្វើពេទ្យអីខ្លះហើយបានទៅថៃ?

មុំន ៖ ហ្នឹងនៅតាមនឹងពេទ្យដូចខ្ញុំថា ។

ឈុនលី ៖ យូរទេ មីង?

ម៉ុន ៖ យូរដែរជាងម៉ាឆ្នាំ ។

ឈុនលី ៖ ហេតុអីបានទៅថៃ?

ម៉ុន ៖ ទៅថៃសភាពថាមិនស្រួល វៀតណាមយើងគ្មានទៅណា មានតែទៅថៃព្រោះព្រំដែននៅនឹង ។

ឈុនលី ៖ អានឹងជំរំ?

ម៉ុន ៖ ខ្ញុំទៅអត់បានចូលជំរំ គ្មានកាកបាទអីណា ។

ឈុនលី ៖ នៅណា?

ម៉ុន ៖ ខ្ញុំនៅជំរំធម្មតា មិនទាន់រំសាយ យើងទៅដល់ដំបូងគេហៅជំរំសែនៗនឹងបើយើងនិយាយទៅងាររគេទេ ងារដូចថាគេស្រឡាញ់គ្នានៅជំរំនឹង គេសែននៅនឹងម៉ង ដល់អីចឹងគេហៅជំរំសែននឹងទៅយកគ្នាអីចឹងឯង ។

ឈុនលី ៖ មីងទៅនៅនឹងមីងមានគ្រួសារ?

ម៉ុន ៖ ខ្ញុំនៅនឹងមានគ្រួសារហើយ កូនឡើង៣ ។

ឈុនលី ៖ មានគ្រួសារតាំងពីអង្កាល់?

ម៉ុន ៖ តាំងពីជំនាន់យើង ។

ឈុនលី ៖ កាលនៅត្បាញ់ នៅរោងចក្រ?

ម៉ុន ៖ អត់ទេ នៅយើងព្រំដែន ។

ឈុនលី ៖ ពេលបែកហើយចេញមក៧៩?

ម៉ុន ៖ ហ្នឹងហើយចេញមកបានប៉ុន្មានឆ្នាំទេ កូនខ្ញុំការឥឡូវកូនអាយុបាន២៣ឆ្នាំ ។

ឈុនលី ៖ ទៅនៅជំរំសែននៅជាមួយអ្នកណាគេ?

ម៉ុន ៖ នៅជំរំសែននៅគ្នាច្រើន ។

ឈុនលី ៖ មានអ្នកដឹកនាំខាងខ្មែរយើងទៅ គ្រប់គ្រងប្រជាជនខ្មែរឯង?

ម៉ុន ៖ មាន មិនដឹងអ្នកណាអ្នកណែយើងជំនាន់នឹងមិនសូវចាប់អារម្មណ៍ដូចខ្ញុំថា ចាប់អារម្មណ៍តែខ្លួនឯងធ្វើម៉េចឲ្យតែរស់ក្នុងក្រុមគ្រួសារ ។

ឈុនលី ៖ នៅជំរំប៉ុន្មានឆ្នាំ?

ម៉ុន ៖ ខ្ញុំនៅជំរំនេះ មិនបានកើតឆ្នាំទេ នៅបានតែ៣-៤ថ្ងៃ ខ្ញុំចេញពីជំរំនឹងទៀតហើយ ។

ឈុនលី ៖ ទៅនៅណា?

ម៉ុន ៖ ឆ្ងាយទៅប៉ៃលិន ទៅនៅប៉ៃលិនបានប្រហែលម៉ាខែកន្លះ ឬ២ខែចេញពីប៉ៃលិននឹងមកគេហៅមកនៅកន្ទែង៨៥ ។

ឈុនលី ៖ ជំរំ៨៥?

ម៉ុន ៖ ត្រង់នឹងគេមិនមែនហៅជំរំ ។

ឈុនលី ៖ អានឹងនៅដីថៃ?

ម៉ុន ៖ ចា៎! នៅ៨៥ ។

ឈុនលី ៖ មីងនៅនឹងធ្វើប្រជាជនធម្មតាដូចគេដូចឯង?

ម៉ុន ៖ ចា៎! គេនៅនឹងអត់ទាន់មានប្រធានភូមិ មិនទាន់មានអីទេ នៅតាមគ្រួសារ ។

ឈុនលី ៖ មីងទៅប៉ៃលិននឹងនោជាមួយអ្នកណាគេ?

ម៉ុន ៖ នៅ ទៅជាមួយអ៊ំចៀមៗគាត់ហៅទៅនៅជាមួយគាត់ ។

ឈុនលី ៖ ម៉េចបានគាត់ហៅទៅ គាត់ធ្វើអី?

ម៉ុន ៖ គាត់ហៅទៅ គាត់ឃើញខ្ញុំកូនខ្ចី កូនតូចនោះដល់ទៅ តែមិនមែនហៅទៅជាគ្រួសារទេ ទៅដូចថាម៉ាជំរំនឹងដូចគ្នា៣០០០-៤០០០ ឬ៣០០-៤០០ គេចែកគ្នាហើយ ។ ឥឡូវអ្នកទៅ៨៥ប៉ុន្មានគ្រួសារ អ្នកទៅប៉ៃលិននឹងប៉ុន្មានគ្រួសារ ។ ដល់ខ្ញុំនឹងរស់នៅជាមួយគាត់យូរហើយ គាត់ហៅទៅៗហៅទៅជាមួយ ។

ឈុនលី ៖ គ្រួសារមីងទៅដែរ?

ម៉ុន ៖ ទៅទាំងអស់គ្នា ។

ឈុនលី ៖ ហើយទៅនៅនឹងបានយូរដែរ?

ម៉ុន ៖ ទៅនៅនឹងបានប្រហែលម៉ាខែជាង ។

ឈុនលី ៖ ហើយធ្វើអីនៅនឹង?

ម៉ុន នៅនឹងអត់ធ្វើអី រស់នៅធម្មតា ។

ឈុនលី ៖ មានប៉ុន្មានគ្រួសារទៅជាមួយមីង?

ម៉ុន ៖ ច្រើនណាស់តាំងពីគ្រួសារខាងទ័ពខាងអីទៅទាំងអស់ ព្រោះខ្ញុំនៅខាងមន្ទីរទេ ខាងសេដ្ឋកិច្ច គ្រួសារគ្រប់គ្រងខាងសេដ្ឋកិច្ច ខាងអង្ករកាកបាទអីនឹងគេដឹកមកយើងគ្រប់គ្រងអង្ករនឹងមកសម្រាប់ចែកចាយប្រជាជន ។

ឈុនលី ៖ មីងការឆ្នាំណា បើនៅបាន៣-៤ឆ្នាំការ?

ម៉ុន ៖ នៅបានយូរដែរ ដូចអាយុ២៧ ដកកូនដឹងអាយុ ព្រោះការភ្លាម មានកូនភ្លាម ។

ឈុនលី ៖ ខ្ទង់ឆ្នាំ៨៣?

ម៉ុន ៖ ៨១ កូន ។

ឈុនលី ៖ ហើយដល់ពេលចេញពីប៉ៃលិនម៉េចបានចេញពីនោះ?

ម៉ុន ៖ ចេញពីប៉ៃលិនវាទៅសម្រាកភ្នំ វាឈឺច្រើនពេក អូ!ផាប់អស់ទាស់ហើយ អ្នកផាប់វាជ្រលងចេះ ដល់ផាប់ពេកទៅមេខាង៨៥គាត់ហៅឲ្យនៅ ។

ឃុនលី ៖ មេ៨៥អ្នកណាគេ?

ម៉ុន ៖ ដឹងអ្នកណាគេ ដឹងអ្នកណាមើល មានតាវុធហៅតាវុធ ដឹងអ្នកណាអ្នកដឹកនាំច្របូកច្របល់ ចុះមានកងទ័ពនៅនឹង ប្រជាជនក៏នៅនឹងវាចំរុះទាំងអស់ ដល់អីចឹងមិនដឹងជា ។ ហើយមេគ្រប់គ្រងរួមម៉ង ដូចខ្ញុំថាខ្ញុំអត់សូវដឹងអីទេ ។

ឃុនលី ៖ ដល់ពេលមីងចេញពីប៉ៃលិនមកនៅកន្លែង៨៥នឹង?

ម៉ុន ៖ ចាំ!

ឃុនលី ៖ នៅបានប៉ុន្មានឆ្នាំ?

ម៉ុន ៖ នៅបាន៣ឆ្នាំ ២ ។

ឃុនលី ៖ មីងចាំពេលទៅជំរំ៨៥ឆ្នាំណា?

ម៉ុន ៖ អឺ!៨៥ ខ្ទង់៨០ប៉ុន្មានយើងចេញមកវិញ ។ គេអ្នកដឹកដូចគាត់និយាយអ្នកណាអត់ចំកន្លែងអត់ ដូចខ្ញុំមានចំកន្លែងគេដឹកអត់ទៅ ។

ឃុនលី ៖ ចុះមកជំរំគេមកកត់ឈ្មោះ?

ម៉ុន ៖ អត់ខ្ញុំមិនមែននៅចំជំរំកាកបាទចិញ្ចឹមណា ។

ឃុនលី ៖ មីងនៅ៨៥ ប៉ុន្តែជំនួយខាងណាឲ្យ?

ម៉ុន ៖ ជំនួយខាងរាជរដ្ឋាភិបាលខ្មែរក្រហម ឧបត្ថម្ភ ។

ឃុនលី ៖ បានន័យថាជំរំ៨៥នឹងមានអ្នកឧបត្ថម្ភ២ផ្នែក មួយខាងកាកបាទក្រហម មួយទៀតខាងខ្មែរក្រហម?

ម៉ុន ៖ ចាំ! ហើយដឹងថាខាងខ្មែរក្រហមនឹងឯង អង្ករបាវៗដល់ពេលបើកអង្ករគេមានកំណត់ប៉ុន្មានថ្ងៃខែយើងទៅបើម្តង ។

ឃុនលី ៖ ហូបគ្រប់គ្រាន់ទេ?

ម៉ុន ៖ ជំនាន់នឹងគ្រប់គ្រាន់ ។

ឃុនលី ៖ លំបាកអត់ អាពេលនៅជំរំនឹង?

ម៉ុន ៖ បើដូចខ្ញុំថា គេអ្នកពិបាកបែបគេលំបាក ខ្ញុំអត់មានស្អីពិបាក ។

ឃុនលី ៖ ចុះមីងថានៅជាមួយអ៊ំៗនៅជាមួយមេៗ?

ម៉ុន ៖ នៅជាមួយមេៗតាំងពីជំនាន់យើងនៅមន្ទីរក្នុង ដែលថាទើបនឹងការហើយមិនទាន់បែក ។

ឃុនលី ៖ នៅបានប៉ុន្មានឆ្នាំ នៅជាមួយមេៗ?

មុ៉ន ៖ នៅបានមិនប៉ុន្មានម៉ាឆ្នាំទេ ។

ឈុនលី ៖ មេណាខ្លះទៅ?

មុ៉ន ៖ មេៗនៅភ្នំពេញអស់ហើយ ។ គេចាប់តែខ្ញុំអត់បាននៅផ្ទាល់ ខ្ញុំនៅខាងដាំបាយដាំអី ។

ឈុនលី ៖ ដាំបាយ?

មុ៉ន ៖ ដាំបាយដូចយើងកងការពារមានប៉ុន្មាន៣០-៤០នាក់ ។

ឈុនលី ៖ ហូបចុកគ្រប់គ្រាន់រហូត?

មុ៉ន ៖ គ្រប់គ្រាន់រហូត ចុះយើងនៅមន្ទីរ គេមិនឲ្យយើងខ្វះ ពេលអ្នកមកពីក្រៅដាំបាយតម្រូវប៉ុន្មាននាក់ ពេលគេមកបើកវគ្គ គ្នា៣០ឬ២០គេប្រាប់ៗយើងដាំបាយតាមនឹងទៅ ។

ឈុនលី ៖ កន្លែងនឹងសុទ្ធតែមេៗគេមកជុំគ្នានៅម៉ាកន្លែង?

មុ៉ន ៖ គេមិនមែនជុំទេ មានមេធំគេនៅណាណៃ គេមិនឲ្យយើងដឹងទេ ជំនាន់នឹង ។

ឈុនលី ៖ បើអ្នកដែលមីងស្គាល់មានអ្នកណាខ្លះ?

មុ៉ន ៖ ស្គាល់ដែលខ្ញុំនិយាយ គាត់នេះអស់មីងសែន គាត់គ្រប់គ្រង គាត់ចល័តមិនមែននៅយើងគ្រាន់ដឹងថាឈ្មោះគាត់ដូចអ៊ំខៀវ សំផន យើងដឹងមេយើងឈ្មោះអ៊ីចឹង តែគាត់មិនមែននៅជាមួយយើងគ្រាន់ខ្ញុំនៅមន្ទីរនឹងមែន តែនៅចាំបាយអ្នកនឹង តែគាត់នឹងដូចខ្ញុំថាមិនដែលឲ្យយើងឃើញ គាត់ចល័ត ។

ឈុនលី ៖ នៅនឹងបានម៉ាឆ្នាំ?

មុ៉ន ៖ អឺ!

ឈុនលី ៖ ការហើយនៅនឹង?

មុ៉ន ៖ ការហើយនៅនឹង មុននឹងការនឹងចេញពីមន្ទីរនឹងទៅគ្រប់គ្រងខាងសិល្បៈ ។

ឈុនលី ៖ នៅណា?

មុ៉ន ៖ សិល្បៈនៅនឹងដែរ ។

ឈុនលី ៖ គ្រប់គ្រងរបៀបម៉េច?

មុ៉ន ៖ គ្រប់គ្រងយើងដូចថា ចេះតែថា មិនបានរាំ ដឹកនាំគេ គ្រាន់ធ្វើខ្លួនឲ្យគេ ។

ឈុនលី ៖ សិល្បៈនឹងគេធ្វើអីខ្លះ គេរាំគេច្រៀង?

មុ៉ន ៖ គេរាំដូចថាឥឡូវគេរាំជាក្រុមៗ ចេញមានរាំរបាំក្អោក របាំគោះត្រឡោក របាំអប្សែ្រ របាំបាច់ផ្កា របាំគ្រាប់ ។

ឈុនលី ៖ រត់មកដល់នឹងហើយមានបង្កើតក្រុមរបាំទៀត?

មុ៉ន ៖ ចា៎! បង្កើតក្រុមរបាំដូចពូទៅជួបមួយនោះ ។

ឈុនលី ៖ ខាងសិល្បៈនឹង សុទ្ធតែអ្នកដែលមកពីភ្នំពេញ មិនមែនអ្នករើសថ្មីនៅនេះទេ?

ម៉ុន ៖ អត់ទេ អ្នកដូចថាមកគស៊ូជាមួយយើងចាស់ៗម៉ាជំនាន់នឹងទៅ រើក្មេងៗនឹងបង្កើតក្រុមសិល្បៈ។

ឈុនលី ៖ បានប៉ុន្មាននាក់?

ម៉ុន ៖ ច្រើនដែរនឹង៣០-៤០នាក់ទៅ មានក្មេងមានអីដូចតែយើងសព្វថ្ងៃនឹង។

ឈុនលី ៖ មីងកាន់ម៉ាក្រុមនឹង?

ម៉ុន ៖ ចា៎! កាន់ទៅគេថាទៅសម្តែងនៅគីឡូ១២នាំក្រុមសិល្បៈនឹងទៅ។

ឈុនលី ៖ នាំទៅជិះអីទៅ?

ម៉ុន ៖ ដើរទៅ។

ឈុនលី ៖ ចុះអីវ៉ាន់អីៗ?

ម៉ុន ៖ ហ្នឹងហើយកាន់ទៅ ខោអាវជំនាន់នឹងក៏មិនច្រើនដូចយើងឥឡូវដែរ។

ឈុនលី ៖ ខោអាវស្លៀកសិល្បៈនឹងស្លៀកម៉េចទៅ ខោអាវខ្មៅ?

ម៉ុន ៖ អត់ មានពណ៌ក្រោកនោះពណ៌ដូចក្រោក មានធ្វើកន្ទុយក្រោកអីចឹងធ្វើស្លាបធ្វើអីដូចគ្នា។

ឈុនលី ៖ ហើយកម្មវិធីអីគេ មានអ្នកសិល្បៈទៅសម្តែង?

ម៉ុន ៖ មានកម្មវិធីពេលជប៉ុន ពេលអីមក។

ឈុនលី ៖ មកដល់តំបន់នឹងហើយ មានគេមកទៀត?

ម៉ុន ៖ មានផ្ទះសារតាំងៗមានភ្ញៀវគេមក កន្លែងសារតាំងក្រោយ។

ឈុនលី ៖ ជិតជាយដែន?

ម៉ុន ៖ សារតាំងៗនឹងដូចថា កន្លែងសម្តេចដូចថាយកសារយកអីមកជួបជុំគ្នា។

ឈុនលី ៖ រាំសិល្បៈឲ្យមើល?

ម៉ុន ៖ ចា៎! ដល់អីចឹងមានសិល្បៈជប៉ុនមានអីគេមកសម្តែងឲ្យយើង យើងក៏សម្តែងឲ្យគេមើលសិល្បៈយើង។

ឈុនលី ៖ ចេញពីសិល្បៈនឹងមីងទៅប៉ៃលិន?

ម៉ុន ៖ អត់ទេ ចេញពីសិល្បៈនឹងទៅ យើងមានកូនមានចៅបែកគ្នាទៀត។

ឈុនលី ៖ ទៅណា?

ម៉ុន ៖ បែករៀងខ្លួនដូចថារកមុខរបររៀងៗខ្លួន លែងមានក្រុម លែងមានបក្សពួក។

ឈុនលី ៖ អានឹងឆ្នាំណា?

ម៉ុន ៖ ដល់សួរឆ្នាំអីចឹងភ្លេចអស់ហើយ។

ឈុនលី ៖ តែពេលនឹងមកពីប៉ៃលិន?

ម៉ុន ៖ ចា៎!មក ។

ឈុនលី ៖ មកពីថៃ?

ម៉ុន ៖ ដែលបែកចេញពីប៉ៃលិនអានឹងមានកូនមានអីគ្រប់ អានឹងខ្ញុំឈប់គ្រប់គ្រងនឹងហើយ អាសិល្បៈនឹងក៏យើងរំសាយពេលរត់នឹងទៀត ។

ឈុនលី ៖ ពេលនឹងមកពីថៃវិញសិល្បៈ?

ម៉ុន ៖ សិល្បៈនឹង យើងនៅនេះ បានយើងចេញទៅថៃនឹង យើងឈប់សិល្បៈអីហើយ ។

ឈុនលី ៖ បើគិតទៅខួងឆ្នាំ៨៣ ៨៤?

ម៉ុន ៖ ហ្នឹងហើយអាចនឹងឯង ។

ឈុនលី ៖ មីងមកពីជំរំថៃវិញខួង៨៦ ៨៧ មកវិញធ្វើអី?

ម៉ុន ៖ មកវិញត្រូសត្រាយដីធ្វើផ្ទះ អានឹងចាប់ផ្តើមរាវមីង មុនមកនឹង ខ្ញុំមកក្រោយគេទៀត ក្រោយគេបង្អស់ ព្រោះប្តីខ្ញុំបើកឡានដឹកប្រជាជនដឹកទ័ពស្អីៗប្រជាជនអីនៅនឹង ដឹកមកអស់មានគេមានទីលំនៅអីបានខ្ញុំចេញមកក្រោយគេ ។

ឈុនលី ៖ មកក្រោយគេ មានដីនៅស្រាប់?

ម៉ុន ៖ ដីនៅក្រោយគេចាប់ទុកឲ្យយើង គេដឹងថានៅក្នុងកងនឹងដែលគាត់គ្រប់គ្រងនឹង មានគ្នាប៉ុន្មាន ១០-២០នាក់ គេមកមុនគេចាប់ទុកឲ្យយើងសម្រាប់មេដឹកនាំនៅខាងសេដ្ឋកិច្ចនឹង ។

ឈុនលី ៖ កាលនឹងបានកូនប៉ុន្មាន?

ម៉ុន ៖ កូន៥ ។

ឈុនលី ៖ ទៅនៅជំរំមានកូនតូច?

ម៉ុន ៖ ទៅជំរំនឹងអានឹងកូនទី៣ កូនតូចកំពុងតែដើមទៅសម្រាលនៅជំរំនឹងឯង ។

ឈុនលី ៖ នៅជំរំមានកូនមួយទៀត?

ម៉ុន ៖ ចា៎! នៅសម្រាលនៅជំរំនឹងហើយបានទៅប៉ៃលិន ចេញពីប៉ៃលិនមក ។

ឈុនលី ៖ អានឹងជំរំ៨៥ ឬជំរំស្អី?

ម៉ុន ៖ ជំរំសែន ។

ឈុនលី ៖ ដល់ពេលទៅប៉ៃលិន មកនៅ៨៥ហើយ បានចេញមកនៅនេះ?

ម៉ុន ៖ ចា៎!នៅ៨៥ មកនៅនេះ ។

ឈុនលី ៖ នៅភូមិអីគេ?

ម៉ុន ៖ ភូមិដូង ។

ឈុនលី ៖ ផ្ទះនឹង?

ម៉ុន ៖ ចាំ! អត់ទេ ផ្ទះមុននៅក្នុងនោះ ។

ឈុនលី ៖ ភូមិដូចដែរ?

ម៉ុន ៖ ចាំ!

ឈុនលី ៖ ចុះផ្ទះនេះមកនៅ?

ម៉ុន ៖ ផ្ទះនេះនៅជំនាន់អ៊ុនគាត់ ។

ឈុនលី ៖ ចុះពេលមីងចេញពីថៃមកនឹង នៅធម្មតា ឈប់កាន់កងកាន់អីទៀត?

ម៉ុន ៖ ឈប់ ។

ឈុនលី ៖ ចុះគ្រួសារមីង?

ម៉ុន ៖ គ្រួសារខ្ញុំក៏ឈប់នៅសេដ្ឋកិច្ចនឹងទៅកាន់ម៉ែខលដែលខ្ញុំនិយាយមិញ អាគេកាយធ្វើផ្លូវធ្វើអី គ្រួសត្រាយផ្លូវតាមនឹង ផ្ទះមីន ផ្ទះអីផង ដែលផ្លូវនឹងផ្លូវគ្រួសារខ្ញុំគ្រួសត្រាយដំបូង ។

ឈុនលី ៖ ដែលគាត់អ្នកបើកឡានកំទេចមីន?

ម៉ុន ៖ អត់ទេ បើកដូចថាមានគេរាវយើងទៅគ្រួសត្រាយផ្លូវទៅ ហើយជំនាន់រាវនឹងអត់មានម៉ាស៊ីនណា នាំឆ្កើសៗ ។

ឈុនលី ៖ គ្រោះថ្នាក់?

ម៉ុន ៖ គ្រោះថ្នាក់ ជួនកាលផុតជើង ផុតដៃទៅ បានខ្ញុំភ្លេចអស់ បាត់ការចងចាំតាំងពីនឹងមក ជំនាន់នឹងមានពោះធំៗមានប្តីនៅជាមួយមែន ប្តីមិនដែលដូចថាទៅវៃទៅមុខអីនឹង នៅជាមួយនៅជាមួយគ្រួសារនឹង តែភ័យគ្រាន់ថាគាត់ដឹកមកនៅនឹងហើយបន្តិចផ្ទុះមីនត្រង់នេះ ចាប់ផ្តើមខ្លួនឯងញាក់ហើយ ។

ឈុនលី ៖ ពុខ្លាំង?

ម៉ុន ៖ អត់ពុទេ គេប្រាប់មកថាឥឡូវទៅដឹកនអ្នករបួសដាច់ជើងដាច់ដៃគ្រួសារខ្ញុំអ្នកដឹក ។

ឈុនលី ៖ ហើយរស់នៅរហូតដល់ខ្ទង់ឆ្នាំ៨៨ ៨៩ ធ្វើអី?

ម៉ុន ៖ ខ្ញុំហ្នឹង ។

ឈុនលី ៖ ទទួលជំនួយទៀតទេ ពេលនឹងមានបើកស្បៀងបើកអី ខាងខ្មែរក្រហមគេជំនួយមក?

ម៉ុន ៖ បើក អានឹងនៅបើក ។

ឈុនលី ៖ បើកដល់ណា?

ម៉ុន ៖ នៅបើកដល់៨៧ ៨៨ ឈប់ ។

ឈុនលី ៖ បានអីបើគេឈប់?

ម៉ុន ៖ ឈប់យើងកកើតរួមគ្នាធ្វើស្រែចំការ ។

ឃុនលី ៖ គេឈប់ឲ្យ៨០ជាង?

ម៉ុន ៖ ចា៎! ខ្ញុំមកនៅនេះបានប៉ុន្មានឆ្នាំ គេឈប់បើក ។

ឃុនលី ៖ ដល់ឆ្នាំ៩០ ដល់បោះឆ្នោត?

ម៉ុន ៖ ហ្នឹងអាចជិនាន់នឹងឯង អាស្កុរនឹងគេនៅឲ្យខ្វះ អ្នកអត់អ្នកអីទ័ពនឹង ។

ឃុនលី ៖ តែមីងបានគ្រប់គ្រាន់ទេ?

ម៉ុន ៖ បាន ផ្ទះខ្ញុំមានលក់ទៀត តែលក់អត់កើត ។

ឃុនលី ៖ របៀបថាធ្លាប់ធ្វើ ធ្លាប់គ្រប់គ្រងគេពីមុនមកគេឲ្យយើងច្រើន?

ម៉ុន ៖ អត់ទេ គិតតាមកូន គេអត់មានឲ្យលើសពីប្រជាជនទេ ។

ឃុនលី ៖ អានឹងគេឈប់ត្រឹមឋានៈ ដំណែង?

ម៉ុន ៖ តាំងពីដើមមកគេអត់មានគិតតំណែងអីទេ គេគិតថាយើងកូន៥គេចែកតាមកូន កូនឯងកូន ២ គេចែកតាមកូន២ ចែកដូចថាមាត់ច្រើនគេចែកតាមមាត់ច្រើន ។

ឃុនលី ៖ មីងមានហូបសល់?

ម៉ុន ៖ ហូបសល់ ចុះខ្វាញ់គេបើកមកទាំងធុង យើងហូបម៉េចអស់ ត្រីខត្រីអី ។

ឃុនលី ៖ ប៉ុន្មានខែបើកម្តង?

ម៉ុន ៖ អានឹងម៉ាខែ កន្លះខែគេកំណត់គេទៅបើកឲ្យម្តង មានប្រហុកមានអំបិលមានអីសព្វគ្រប់ទាំងអស់ ។

ឃុនលី ៖ ហើយយើងដាំបន្លែដាំអីទៅ?

ម៉ុន ៖ យើងអ្នកនេះនឹងមានដីមានធ្លីយើងដាំទៅ ។

ឃុនលី ៖ អានឹងជំនួយខ្មែរក្រហមឬជំនួយខាងកាកបាទ?

ម៉ុន ៖ អាបើកអង្ករនឹងជំនួយខាង កាកបាទគេគិតតែជំរំទៅ ។

ឃុនលី ៖ ចុះដល់ពេលខ្វង់បោះឆ្នោត នៅនេះ?

ម៉ុន ៖ នេះអត់មានអីផង ។

ឃុនលី ៖ យើងៗតែយើង គេបោះគេក្នុង?

ម៉ុន ៖ ចា៎! អ្នកបោះទៅបោះនឹងគេទៅ បោះនៅនឹងយើង ។

ឃុនលី ៖ ចុះដល់ពេលក្នុងពេលនឹង មីងថាអ៊ំៗនឹងគាត់ទៅណាវិញ?

ម៉ុន ៖ ដឹងគាត់ទៅណា ដឹងគាត់ទៅនៅកន្លែង អត់ដឹងគាត់ទីតាំងនៅណាទេ ដឹងថាអ៊ំប៉ុលពតដែលស្លាប់នឹងទៅនៅដងរែកនឹង ក៏មីងនឹងក៏មិនដឹងដែរ ទាល់តែស្លាប់ហើយបានគេថាគាត់ទៅនៅ

ដងវែក ។ ចុះមេដឹកនាំជំនាន់នឹង គេអត់ដូចយើងរដ្ឋាភិបាលទៅនេះទៅនោះដឹងទេ ។ សូម្បីរដ្ឋាភិបាលរាល់ថ្ងៃនេះ ទោះបីជាយើងថាគាត់ទៅទស្សនកិច្ចនៅនេះនៅនោះ ប្រជាជនយើងខ្លះក៏មិនដឹង ៗ តែគ្នាគាត់ធំៗនឹង អានឹងអីចឹងដែរ ។ បើយើងនិយាយថាឯកអាមាត្យតូចតាចយើងអត់ដឹងទេ ។

ឈុនលី ៖ ចុះដល់ពេលយើងផ្តាច់ខ្លួននេះឆ្នាំប៉ុន្មាន ចូលសមាហរណកម្ម?

ម៉ុន ៖ សមាហរណកម្ម ៩០គត់ ។

ឈុនលី ៖ ៩៦ ៩៧?

ម៉ុន ៖ ៩០ ។

ឈុនលី ៖ អ៊ុនគាក់អត់ទាន់សមាហរណកម្ម?

ម៉ុន ៖ អានឹងអ៊ុនគាក់នៅប្រទាញប្រទុងនៅឡើយទេ ។

ឈុនលី ៖ ប្រទាញប្រទុងនឹងបាញ់គ្នា?

ម៉ុន ៖ ប្រទាញប្រទុងគេបាញ់តែមុខនឹង ខ្ញុំនៅនឹងធម្មតា ។

ឈុនលី ៖ តំបន់ណាដែលគេបាញ់គ្នា?

ម៉ុន ៖ បាញ់គ្នាតំបន់ខ្វាងរាប់ ។

ឈុនលី ៖ ខ្វាងរាប់នៅស្រុកអីគេ?

ម៉ុន ៖ ស្រុកម៉ាឡៃ ។

ឈុនលី ៖ តែកាលមុនអត់ទាន់មានឈ្មោះម៉ាឡៃ?

ម៉ុន ៖ ទេឈ្មោះម៉ាឡៃៗ តាមពីជំនាន់អ៊ុនគាក់គេចាត់ចែងមេះ ឈ្មោះម៉ាឡៃៗ ហើយចេះឆ្លល់រៀងៗខ្លួនឥឡូវម៉េចបានគេដាក់ម៉ាឡៃ ។

ឈុនលី ៖ មីងអត់ដឹង?

ម៉ុន ៖ អត់ដឹង មីងមិនសូវដឹងៗតែខំប្រឹងប្រែងគ្រប់គ្រងតែកូនហើយព្រួយជំនាន់នោះ ។

ឈុនលី ៖ ប្តីមីងអត់មានទៅបាញ់នឹងគេ ហើយដល់ពេលគេបាញ់ខ្ទង់៩០ដាង?

ម៉ុន ៖ ចា៎! អត់មាន ។

ឈុនលី ៖ គាត់នៅផ្ទះ ធ្វើផ្លូវ?

ម៉ុន ៖ ធ្វើផ្លូវ ពេលស្ងាត់ទៅធ្វើផ្លូវ គេថាមិនស្រួលទេ ដើរជីកគ្រង់សេរតាមគ្រឡុកអី បើថានេះអត់ ។

ឈុនលី ៖ ចុះអ្នកណាគេមេការជីកផ្លូវ ធ្វើផ្លូវអ្នកណាមេការ?

ម៉ុន ៖ មេការមានតែគ្នាឯងនឹងឯង ដូចថាគាត់នឹងកាន់ ហើយមេការដែលនេះនឹងតាអៀង សារី ។

ឈុនលី ៖ គាត់កាន់ខាងតំបន់នឹង?

ម៉ុន ៖ គាត់ហ្នឹងហើយ ។

ឈុនលី ៖ ប្រពន្ធគាត់ដែរ?

ម៉ុន ៖ ប្រពន្ធគាត់អត់ដឹង១រឿង ដឹងថាឈ្មោះគាត់គេខាងផ្នែកអ៊ំស្រី អ៊ំប្រុសនៅខាងណាអត់សូវដឹងដែរ ។

ឈុនលី ៖ កាលនឹងគេហៅអ៊ំ?

ម៉ុន ៖ ហៅអ៊ំ១អៀង សារី តាអៀង សារី ស្រេចតែយើងហៅ តាប៉ុលពត ។

ឈុនលី ៖ អត់ដែលឃើញមុន?

ម៉ុន ៖ អត់ឃើញអត់ អ្នកឃើញ ។

ឈុនលី ៖ មីងដែលឃើញ?

ម៉ុន ៖ ចា៎! ដែលឃើញៗគាត់មកលេងក្មួយៗនឹងទៅបាត់ទៅគាត់មិននៅទេ ទៅដីថៃ មកអីចឹងទៅយើងមីង១នៅតាមក្រសួងមន្ទីរ គាត់មកលេងគាត់ទិញស្ករគ្រាប់ជូនក្មេង១លេង នំនែកអីតិចតួច ។

ឈុនលី ៖ ដូចរបៀបយើងធម្មតា?

ម៉ុន ៖ ធម្មតា ។

ឈុនលី ៖ គេឈប់ប្រទាញប្រទុងតាំងពីឆ្នាំណា? អាយើងមកពីថៃវិញ?

ម៉ុន ៖ អាអ៊ុនតាក់ ។

ឈុនលី ៖ អ៊ុន តាក់ ៩០គត់៩១ ៩២ ៩៣បោះឆ្នោត?

ម៉ុន ៖ ហ្នឹងហើយនៅនឹងម៉ង អត់មានទៅណាទៅណៃទៀតទេ ។

ឈុនលី ៖ ចុះ៩៤ ៩៥?

ម៉ុន ៖ ៩៤ ៩៥ នឹងយើងត្រូវគ្នាផ្ដាច់ខ្លួនហើយអស់ហើយ ។

ឈុនលី ៖ មិនមែនត្រូវ៩៦? អាពេលសម្ដេចមកចរចាគ្នា?

ម៉ុន ៖ ពេលសម្ដេចយើងឥឡូវនេះ អានឹងជំនាន់ណា ជំនាន់សម្ដេចហ៊ុន សែនមកជាមួយប្រពន្ធគាត់នឹង អានឹងហើយជំនាន់នឹង ។

ឈុនលី ៖ ៩០គត់ ឬ៩៦ បោះឆ្នោតហើយឬនៅគាត់មកនឹង?

ម៉ុន ៖ បោះឆ្នោតជំនាន់អ៊ុនតាក់ ។

ឈុនលី ៖ អ៊ុនតាក់៩០គត់ ៩១ ៩២ ៩៣បានបោះ?

ម៉ុន ៖ គាត់មកនឹងមុនបោះឆ្នោត ។

ឈុនលី ៖ មុន ឬក្រោយ? ពួកអ៊ុនតាក់មក៩៣គេរៀបចំបោះឆ្នោត?

ម៉ុន ៖ អានឹងឯង គេរៀបចំបោះឆ្នោត នឹងនៅតាមព្រំដែនយើងខាងតាកនខាងអីគេមិននៅវៃ យើងដែលត្រូវគ្នាក្រោយគេ ។

ឈុនលី ៖ ព្រោះចេះបើសិនអ៊ុនតាក់ទៅហើយ៩៣មកហើយ វាអាច៩៣ ៩៤ ព្រោះ៩៣អ៊ុនតាក់បោះឆ្នោត ។ អ៊ុនតាក់គេមក៩០មែន តែគេនៅរៀបចំប៉ុន្មានឆ្នាំនោះ?

ម៉ុន ៖ ទៅភ្នំពេញទៅជាមួយសម្តេចដែរមកនឹង ខ្ញុំទៅលើកដុះទៅជិះកាបាល់ហោះនឹង តាមគាត់ដែលមកនឹង ។

ឈុនលី ៖ ចុះម៉េចបានគេឲ្យយើងទៅជិះ?

ម៉ុន ៖ ចុះយើងមានខ្សែរយៈដែលរាប់អាន ។

ឈុនលី ៖ ហើយប៉ុន្មាននាក់ដែលបានជិះទៅ?

ម៉ុន ៖ ខ្ញុំម៉ាគ្រួសារខ្ញុំ ទៅទាំងអស់គ្នា បើនិយាយទៅគ្រួសារខ្ញុំវាសក្តិពដែរ គាត់ស្គាល់គេ ។ ពេលនឹងខ្ញុំមិនដឹងថាបានទៅផងទេ ដល់ពេលមកគេស្រែកទៅរៀបចំខ្លួនទៅលេងស្រុក ។

ឈុនលី ៖ គ្រួសារមីងគាត់រស់ដល់សព្វថ្ងៃ?

ម៉ុន ៖ គាត់នៅរាល់ថ្ងៃ ។

ឈុនលី ៖ គាត់ធ្វើអីគេ?

ម៉ុន ៖ គាត់នៅខាងកងវិស្វកម្ម ។

ឈុនលី ៖ គាត់ឈ្មោះអីគេ?

ម៉ុន ៖ ហែម ប៊ុន ហឿន ។

ឈុនលី ៖ អាយុប៉ុន្មានហើយ?

ម៉ុន ៖ អាយុ៥៧ នៅចោមចៅបន្ទាយ ។

ឈុនលី ៖ ចុះដល់ពេលក្រោយមកមីងថារស់នៅនឹង ចាប់ផ្តើមធ្វើមេភូមិឆ្នាំណា?

ម៉ុន ៖ ធ្វើមេភូមិមិនដឹងឆ្នាំណាទេ តាំងពីកកើតមក ខ្ញុំឲ្យតែនិយាយរឿងឆ្នាំអត់ចាំ ។

ឈុនលី ៖ ពេលសមាហរណកម្មហើយនឹង?

ម៉ុន ៖ អឺ!

ឈុនលី ៖ ពេលហើយភ្លាមគេរើសមេភូមិ?

ម៉ុន ៖ ទាល់តែបានប៉ុន្មាន ។

ឈុនលី ៖ គេបង្កើតស្រុកម៉ាឡៃ?

ម៉ុន ៖ ចា៎! បង្កើតស្រុកម៉ាឡៃ ហើយគេចែកជាភូមិ ។

ឈុនលី ៖ បង្កើតភូមិឃុំមីងចូល?

ម៉ុន ៖ ចា៎! ចូលនឹងគេរើស គេមកសរសេររើសឲ្យចូលឲ្យធ្វើចេះចុះដល់ប្រជាជនយើងគ្រប់គ្រង ។

ឈុនលី ៖ មីងគិតថានៅពេលដែលក្រោយសមាហរណកម្មហើយ មីងរស់នៅស្រួលជាងពីមុនឬយ៉ាង ម៉េចអំឡុងពេលមុនសមាហរណកម្ម មីងគិតថាមួយណាល្អ សេរីភាព?

ម៉ុន ៖ សេរីភាពដែលម៉ាយើង ដូចអត់មានអ្នកណាលំបាកអ្នកណាស្រួល បើរស់នៅមានដីមានធ្លី មានកូនមានចៅ ។

ឈុនលី ៖ មួយណាដូចមួយណា?

ម៉ុន ៖ ចា៎! បើគិតទៅនោះក៏ដូចគ្នា ទៅនោះទៅក្នុងយើងអត់មានដីមានធ្លី យើងចេះនៅនេះទៅ ។ ថៃវាក៏ចិញ្ចឹមខ្ញុំដែរ ។

ឈុនលី ៖ ម៉េចបានគេជួយគ្រួសារមីង?

ម៉ុន ៖ ព្រោះគ្រួសារខ្ញុំគាត់ទៅស្រុកថៃទៅអារញ្ញ រដ្ឋសុំទាំងអស់ សុំចិញ្ចឹមប៉ុន្មានឆ្នាំ បានឲ្យយើង មានដើមទុករកស៊ី នឹងគេឈប់ចិញ្ចឹមយើង ។

ឈុនលី ៖ តាំងឆ្នាំណា?

ម៉ុន ៖ អាឆ្នាំយើងផ្ដាច់ខ្លួននឹងមកនៅនេះ ខ្ញុំអត់ទៅនៅ ។

ឈុនលី ៖ ហេតុអីបានអត់ទៅ?

ម៉ុន ៖ នឹកឃើញកូនសុទ្ធតែស្រីទៅនៅទៅខ្លាចមានប្ដីនៅថៃយ៉ាងម៉េចៗជនជាតិគេ ខ្មែរយើងនៅតែ នឹក ទោះបីអាក្រក់ល្អនៅតែស្រឡាញ់សាសន៍យើងពូជពង្សយើង ។

ឈុនលី ៖ មីងគ្រួសារកងវិស្សកម្ម បើគិតតាមសក្ដិប៉ុន្មាន?

ម៉ុន ៖ សក្ដិ៣ ។

ឈុនលី ៖ គាត់ទៅមក?

ម៉ុន ៖ ពេលគេហៅទៅ ។

ឈុនលី ៖ ទៅប៉ុន្មានអាទិត្យ ប៉ុន្មានខែបានទៅលេងផ្ទះម្ដង?

ម៉ុន ៖ ទៅ គាត់មិនដែលទៅនៅជាប់នឹង ជាប់កាលម្ហូកគាត់ធ្វើផ្លូវនៅវាលវេញនឹងបានម៉ាខ្សែ ផ្លូវ ជាតិ ។ បានតាំងពីនឹងមក យើងឈប់ទៅ២-៣ឆ្នាំ បានប្រាក់ខែម៉ាគ្រប់ៗគាត់ ។ គាត់នឹក ឃើញប្រពន្ធកូនអត់ គាត់ឈប់នៅ ។ ដល់ពេលគេត្រូវការអីហៅទៅត្រួតមុខត្រួតអីទៅនៅ តែឥឡូវសុំឈ្មោះគេកាត់ដូចថាយើងលំបាកបម្រើការងារវែងឆ្ងាយ គេអនុគ្រោះធ្វើសំណុំ បែបបទសម្រេចហើយ តែឥឡូវនេះគេថាភ្លុំហើយហៅយើងនឹងទៅសម្រេចថា ត្រូវផ្ទេរ ឈ្មោះយ៉ាងម៉េចៗ នៅភ្លុំហើយ ទាល់ឥឡូវភ្លៀងផ្អាក ។

ឈុនលី ៖ ដល់ក្រោយមកមីងខសង្សាហ៍ទៅលេងស្រុកកំណើត?

ម៉ុន ៖ ទៅ ។

ឈុនលី ៖ ទៅញឹកញាប់?

ម៉ុន ៖ ម៉ាឆ្នាំទៅម្តង ។

ឈុនលី ៖ ខែភ្ជុំ?

ម៉ុន ៖ អត់ទេ យើងទៅភ្នំពេញ ទៅកន្លែងដូចថាខាងគាត់នឹងគេហៅទៅលេង ហួសទៅម៉ែ ។

ឈុនលី ៖ ឥឡូវគាត់អាយុច្រើន ម៉ែ?

ម៉ុន ៖ គាត់៨០ជាងហើយ ។

ឈុនលី ៖ នៅជាមួយប្អូន បង?

ម៉ុន ៖ នៅជាមួយប្អូន ។

ឈុនលី ៖ ចុះបងមីងដែលគាត់ធ្វើទ័ពនឹងគាត់ត្រឡប់ទៅស្រុកវិញនៅឆ្នាំណា?

ម៉ុន ៖ ត្រឡប់ទៅតាំងពីយើងឆ្នាំដែលយើងរត់នឹង គាត់អាច៧៩..គាត់ទៅផ្ទះវិញ ព្រោះគាត់មកបានប៉ុន្មានខែ គាត់ត្រឡប់ទៅវិញ ។

ឈុនលី ៖ មកដល់ទីតាំងនឹងវិញ?

ម៉ុន ៖ មកដល់កោះក្រឡកោះអី ។

ឈុនលី ៖ គាត់នៅធ្វើទ័ពរហូត?

ម៉ុន ៖ ធ្វើរហូត ។

ឈុនលី ៖ រហូតដល់ទៅវិញ គាត់ធ្វើអី?

ម៉ុន ៖ គាត់នៅប្រជាជនធម្មតា ។

ឈុនលី ៖ មីងដល់ពេលមីងធ្លាប់នៅតំបន់ខ្មែរក្រហម ដល់ពេលទៅលេងស្រុកអី មីងគេដែលសួរនាំយើង?

ម៉ុន ៖ អត់អី សុទ្ធតែបងប្អូននៅស្រុកគ្រាន់ទៅដល់គេឃើញយើង គ្រាន់ទៅដល់គេហ៊ូរ គេអរយើងដូចថាតស៊ូមកយូរហើយអត់មានបាត់បង់អីនឹងគេ ។ បងប្អូននៅខាងនោះក៏នៅសុខសប្បាយយើងនៅនេះក៏សុខសប្បាយអត់មានដេញដោលថា ស្អីៗ ។

ឈុនលី ៖ ដូចថាគាត់ខឹងជាមួយយើង ថាយើងចូលជាមួយខ្មែរក្រហម?

ម៉ុន ៖ អត់មានខឹងអីផង ទៅដល់ធម្មតា គេគ្រាន់ថាបើមកមុនយើងទៅលេង មកកាលជំនាន់សម្តេចយាងមក ហើយខ្ញុំទៅជាមួយ បើនៅនឹងបានប្រហែលម៉ាអាទិត្យអី គេចែកដីឲ្យ ។ ហើយខ្ញុំទៅនៅគ្រាន់ទៅលេង បានជាងកន្លះខែតែមិនបានកំណត់ថា ។

ឈុនលី :	ទៅលេងនៅណា?

ម៉ុន :	ទៅលេងផ្ទះម្ដាយ ។

ឈុនលី :	ពេលជិះយន្តហោះទៅនឹង?

ម៉ុន :	ចា៎! ជិះយន្តហោះទៅចុះពោធិ៍ចិនតុង ។

ឈុនលី :	យើងទៅផ្ទះទៅ?

ម៉ុន :	ចា៎!ទៅផ្ទះ ។

ឈុនលី :	គាត់ឃាត់នៅនឹងដែរ?

ម៉ុន :	អត់ឃាត់អីទេ យើងមានប្ដីសី តែគ្រាន់ថាបើយើងមកនៅនេះមេភូមិគេទុកដីឲ្យ តែយើងថានៅម៉េចកើត បើយើងនៅនោះមានផ្ទះមានសម្បែង ចុះផ្ទះយើងលើកហើយ ។ ស្រាប់ក៏អីចឹងទៅគេក៏មិនថាម៉េច ទៅរោមឡើងជិតឈើង ចុះសុទ្ធតែបងប្អូននៅពេញភូមិ បើពោះម៉ែពោះឪពុកគាត់នៅស្រុកនឹង ការគ្នានៅនឹង ។

ឈុនលី :	បើសិនឲ្យមីងទៅនៅនោះនៅកើត រស់នៅខាងស្រុកកំណើត?

ម៉ុន :	អត់អីនៅបាន ។

ឈុនលី :	បើឲ្យទៅរស់នៅនឹង?

ម៉ុន :	ចា៎!នៅបាន គ្រាន់ថាយើងវានៅបានយើងអត់មានដីធ្លីអីនៅ នៅដោយសារបងប្អូនឲ្យហូបឲ្យចុកម៉ារស់ៗ តែគ្រាន់ថាយើងនៅបានដូចនៅស្រុកភូមិខ្ញុំនោះវាដូចនៅនឹងអីចឹងដែរ ផ្ទះសម្បែងអីដូចថាចរិតរស់នៅអីមានគ្រែមានអីអង្គុយអីចឹង អត់ដូចផ្ទះគេដែលខ្ញុំធ្លាប់ទៅលេងវាអត់ដូច ។ ផ្ទះគេនោះបើថាឡើងទៅលេងអីទៅលេងលើផ្ទះ វាអត់មានដូចនៅនេះទេស្រុកខ្ញុំដូចនេះទេ អីចឹងស្រុកខ្ញុំរស់នៅបាន ។

ឈុនលី :	ចុះពេលផ្ដាច់ខ្លួនភ្លាមៗ យើងជាមួយអ្នកស្រុកអ្នកភូមិស្រឡាញ់គ្នាធម្មតា?

ម៉ុន :	ចា៎! អត់អី ។

ឈុនលី :	អត់ដែលមានប្រកាន់?

ម៉ុន :	អត់ ទៅបងប្អូនទាំងអស់ អាមួយមកហើយអញស្មានឯងងាប់គេគ្រាន់ថាអីចឹង អាយុវែងសាច់ថ្លៃ ទឹកដោះម្ដាយថ្លៃ គេអត់មានថាងែងចេះខ្មែរក្រហមអត់ទេ ។ ទាល់សព្វថ្ងៃនឹង ទៅអីចឹង គេជួយ ។

ឈុនលី :	ចុះមីងយល់ថា ក្រៅពីបងប្អូនរបស់មីង មីងគិតថានៅមានគេមិនចូលចិត្តខ្មែរក្រហម ទឹងខ្មែរក្រហម?

ម៉ុន ៖ គេនិយាយៗធម្មតា នៅអាពតស៊ីបាយអីគេបង្កើតសហករណ៍ហូបបាយចេះចុះ គេនិយាយជារឿងរបស់គេ ខ្ញុំជារឿងរបស់ខ្ញុំ គ្មានទោមនស្ស អានឹងយើងរកសេចក្ដីសុខរៀងៗខ្លួន។

ឈុនលី ៖ ធ្វើម៉េចរបបនឹងវាអីចឹង?

ម៉ុន ៖ ចាំ! របបហ្នឹងវាអីចឹង ឲ្យប្រឆាំងគ្នាថាឯងខៀវលប៉ុលពត ហើឯងខៀវលអ្នកនោះអត់ ធម្មតា យើងនិយាយប៉ុនណា បើយើងសួរទៅដូចប្អូនឯង គេសួរថាប្អូនឯងនៅអាពតម៉េចដែរ យើងនិយាយតាមដំណើរនឹងទៅ បើយើងនៅចំកន្លែងស្រួល យើងនិយាយរឿងស្រួល រឿងបាយហូបចុករបៀបរបបយើងធ្វើការយើងធ្វើពេទ្យ យើងនិយាយប្រាប់តាមនឹង ខ្ញុំធ្វើពេទ្យចេះចុះ។ ដល់អីចឹងគេថា ឯងទៅនៅចំកន្លែងស្រួករហូត។ ហើយមកនៅព្រំដែននេះក៏អីចឹង ធ្វើពេទ្យធ្វើអីនៅប្រកសួងមន្ទីរ អត់មានបានទៅដឹកជញ្ជូនអីនឹងគេទេ។

ឈុនលី ៖ ចុះបើតាមមីងគិតកាលលើកមុនគេមានរបបស្រាប់ៗ ពេលប្រៀបធៀបមកឥឡូវយើងរកស៊ីស្រួលឯង មីងគិតថាមួយណាស្រួលជាង?

ម៉ុន ៖ បើយើងនិយាយយើងស៊ីកម្លាំងញើសឈាមគេវាមិនសុខស្រួលទេ។

ឈុនលី ៖ ម៉េច?

ម៉ុន ៖ ចុះវា យើងនឹកឃើញថាបើកភ្នែកមកអាងមានអង្ករស៊ី ដល់អីចឹងជីវិតយើងវាទំរុនទៅតាមនឹង យើងអត់មានគិតខំអនាគត យើងមានស្មារតីភ្ញាក់រលឹកថាឥឡូវអភិវឌ្ឍខ្លួនយើងឲ្យមានស្រែមានចំការអី អានឹងយើងគិតថាដើបមកស្រួល ខ្ញុំថាអត់ស្រួល បើយើងនិយាយអត់មានស្រែចំការអានឹងយើងថាស្រួល។ តែន័យដូចសព្វថ្ងៃនេះ ឲ្យទៅស៊ីកម្លាំងញើសឈាមគេអីចឹងអត់ស្រួល ព្រោះគេបានមកចែកយើងក៏មកមិនបានស្រួលណា រង្គាសពីបងពីប្អូនមក យើងសន្សំលុយទុកសម្រាប់តំកល់ទិញយកមកឲ្យយើងអានឹងមិនស្រួលទេកម្លាំងញើសឈាមគេ។ ទាល់តែយើងខំប្រឹងប្រែងថាណែនាំកូនកុំធ្វើដូចជំនាន់យើងចេះចុះ។ ហើយដូចឥឡូវយើងចិញ្ចឹមកូនប្រៀបធៀប ថាជំនាន់ម៉ែចិញ្ចឹមកូន ហើយសង្គ្រាមទៀតដឹងពិបាកប្រហែល ដល់អីចឹងប្រឹងប្រែងតាមនឹង។

ឈុនលី ៖ បើតាមមីងគិតវាខុសគ្នាយ៉ាងម៉េច ការចិញ្ចឹមកូនរហូតដល់ជំនាន់នេះខុសគ្នាយ៉ាងម៉េចទៅ?

ម៉ុន ៖ ខុសគ្នាគ្រាន់ថាយើងមានកូនមានចៅ បានស៊ីអង្ករស្រាប់ជំនាន់នឹង តែដល់មកកូនយើងវិញមកអង្ករទាល់តែខំប្រឹងប្រែងខ្លួនឯង បើយើងមិនខំប្រឹងប្រែងទេ យើងអត់។ ហើយបើយើងជំនាន់ស៊ីអង្កររួម យើងទោះបីមិនទៅដឹកជញ្ជូនមិនទៅណា ក៏យើងមានអង្ករហូប។ វាខុសគ្នា គឺខុសគ្នាដូចខ្ញុំថា វាម្យ៉ាងម្នាក់។ តែយើងសព្វថ្ងៃនេះ យើងនៅពឹងផ្អែកថាអង្កររួមៗ ក៏ស្រុកទេសយើងមិនរីកចំរើន នៅមានស្រុកគំនិតមួយអាក់អន់ចិត្តថាអញធ្លាប់ស៊ី

អត្ថិរួមចេះ ឥឡូវមកអត្ថិរខ្លួនឯងចេះចុះអី អត់មានគិតអីចឹង ។ ទាល់តែយើងមានគំនិតថារស់ យើងខំប្រឹងប្រែង សព្វថ្ងៃនឹងទៅធ្វើការលំបាក....... ។ ឧទាហរណ៍ដូចខ្ញុំជំពាក់គេ ដល់ធ្វើទៅវាអត់បានយកមកសងគេវិញ វាលំបាកត្រង់នឹង ។ យើងនៅនឹកឃើញដេកគិតថាមិនដឹងធ្វើអីបានសងគេៗ ។

ឈុនលី ៖ នៅគិត ប្រឹងធ្វើខ្លួនឯង?

ម៉ុន ៖ ចា៎!

ឈុនលី ៖ ពេលមីងមកនៅដំបូងនៅទឹកដីនឹងតំបន់នឹង មានអ្នកណាខ្លះគេរស់នៅទាហានផ្សេងៗ?

ម៉ុន ៖ មានខ្មែរក្រហម ចូលមកខ្មែរក្រហម ប្រជាជនដែលយើងរស់នៅសព្វថ្ងៃនេះ អត់មានប្រជាជនសុទ្ធសាធមកពីក្រៅទេ គឺប្រជាជនដែលនៅនឹងចេញពីប្រភពនៅក្រសួងមន្ទីរនិងទ័ព ដូចថាប្រពន្ធទ័ព ។ ដល់ពេលទ័ពខ្លះទៅ ដល់ពេលនេះគេអ្នកធ្វើតទៅទៀតគេអ្នកធ្វើនៅនឹងដែរ ព្រោះប្រជាជននៅនេះ ទ័ពប្ដីទៅមុខ អត់មានទៅតាមប្ដីដូចនៅក្នុងទេ ។

ឈុនលី ៖ យើងនៅក្រោយៗធ្វើអី?

ម៉ុន ៖ ចុះបើទ័ពដូចថាប្ដីគេនៅបន្ទាយនោះ យើងនៅផ្ទះយើង ដល់ម៉ាអាទិត្យម៉ាខែ កន្លះខែ ប្ដីគេមកលេងម្ដង យើងអត់មានអីដូចទៅខាងក្នុង ។ ខ្ញុំឃើញនៅបន្ទាយគ្រួសារខ្ញុំនឹង គេនៅនឹងបណ្ដោយ នៅជាមួយប្ដីប្រពន្ធនៅបន្ទាយ បើពួកខ្ញុំអត់ទេ ចុះបើប្ដីនៅធ្វើទ័ពយើងធ្វើស្រែចំការ អត់មានទៅតាមប្ដីទេ ។

ឈុនលី ៖ ទៅតាមប្ដីខាតពេល?

ម៉ុន ៖ ចា៎! ខាតពេលណាកូនចៅយើងអត់មានអត្ថិរប្រកន្លាំង ។

ឈុនលី ៖ ចុះមីងដូចឧទាហរណ៍ មីងធ្លាប់នៅជាមួយខ្មែរក្រហម មីងខ្មែរក្រហមកូនដែលនិយាយខ្មែរក្រហមកាច?

ម៉ុន ៖ អត់ដែលវ៉ៃកូនផង កូន៥អត់មានដែលវ៉ៃទេ ។

ឈុនលី ៖ អត់ដែលវ៉ៃកូន?

ម៉ុន ៖ កូនវាអត់ដែលឲ្យឃំ ឲ្យកាចអីឲ្យយើងវ៉ៃអត់ ហើយគ្រួសារក៏មិនដែលឲ្យមានប៉ះពាល់ឲ្យឈ្លោះគ្នាអំពើហិង្សាកូនអត់មានដែរ ។ ទើបមករឿងដឹកស៊ីខ្លាំង ថាឲ្យចាស់ចំណាស់នេះហើយ..........មិនដែលគេឡូឡាអីអត់ ។

ឈុនលី ៖ មីងឧទាហរណ៍ថាបើយើងចង់ផ្សះផ្សាគ្នាជាមួយខ្មែរក្រហម និយាយទៅប្រជាជនដែលធ្លាប់រងគ្រោះ អ្នកធ្វើការហត់ខ្លាំង មីងគិតថាតើគួរតែផ្សះផ្សាទាល់តែអ្នកនឹងនៅផ្ទះជិតគ្នា ឬមួយនៅឆ្ងាយពូគ្នាបានអាចផ្សះផ្សាគ្នាបាន ត្រូវរូវគ្នាបាន?

ម៉ុន ៖ អត់ទេ! នៅឆ្ងាយ នៅត្រង់ណាក៏ដោយ ខ្ញុំយល់ញាតិ មិនដែលទៅប្រកាន់ថាខាងនេះខាងអ្នកក្នុងអ្នកនៅតាមព្រំដែនអីអត់ទេ ។

ឈុនលី ៖ ចុះឧទាហរណ៍ថាមនុស្សម៉ាក្រុម កំពុងនិយាយគ្នាថាខ្មែរក្រហមអាក្រក់ ហើយមីងពូមីងធ្វើម៉េចទៅ?

ម៉ុន ៖ អត់ទេ ធម្មតាអីចឹងទៅ អ្នកណានិយាយអីនិយាយទៅ អត់មានទៅទោមនស្សឯងនៅខ្មែរក្រហមប្រកាន់ថាមេឯងមេគេអីអត់ទេ ធម្មតាអីចឹងឯង ។ បានខ្ញុំថាសុំតែសុខទេ ជិនាន់នឹងគណបក្សហ៊ុនស៊ីប៉ិច សមរង្ស៊ី បែងចែកគណបក្សក៏ដោយ ក៏ខ្ញុំនៅតែប្រជាជនធម្មតា ។ អត់មានថាគណបក្សនេះគណបក្សនោះ ។

ឈុនលី ៖ អរគុណមីងណា ។

ម៉ុន ៖ ចា៎!

«ចប់»